# សេចក្តីវិភាគ

## ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល

### ក) វិធីសាស្រ្តនៃការវិភាគ

ការវិភាគនេះផ្អែកលើអត្ថបទនៃសេចក្តីព្រាងច្បាប់ស្តីពីសមាគមនិង អង្គការមិនមែនរដ្ឋាភិបាល ដែលបានទទួលក្រៅផ្លូវការដោយអង្គការ CCC ថ្ងៃទី ៨ ខែមិថុនា ឆ្នាំ ២០១៥។

ការវិភាគនេះនឹងពិនិត្យមើលមាត្រានិមួយៗនៃសេចក្តីព្រាងច្បាប់ និងព្យាយាម បង្ហាញពីចំណោទទាក់ទងនឹងមាត្រានោះ។ បន្ទាប់មក មានការវិភាគលើចំណោទទាំងនោះ ផ្អែកលើក្របខណ្ឌគតិយុត្តជាតិ និង អន្តរជាតិ។ ក្របខណ្ឌគតិយុត្តអន្តរជាតិ មានជាពិសេស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ ដែលកម្ពុជាបានធ្វើសច្ចាប័ន។ សេចក្តីអធិប្បាយទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស ក៏ត្រូវបានលើកយកមកដែរ ព្រោះសេចក្តីអធិប្បាយនេះដាក់កាតព្វកិច្ចលើប្រទេសកម្ពុជាផងដែរ។

នៅចុងបញ្ចប់នៃការវិភាគនីមួយៗ មានធ្វើសេចក្តីសន្និដ្ឋាន បើសិនជាមានមាត្រាណាមួយស្របឬមិនស្របនឹងក្របខណ្ឌគតិយុត្តិទាំងនោះ។

### ខ) សេចក្តីវិភាគ

| ល.រ | មាត្រា | ការវិភាគ | មតិ/យោបល់ |
|---|---|---|---|
| ១ | ១ | **មាត្រា ១៖ កិច្ចធានាការពារសិទ្ធិនិងសេរីភាពក្នុងការបង្កើតសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល**<br><br>**ចំណោទ៖**<br>តើ "ការធានាការពារសិទ្ធិនិងសេរីភាពក្នុងការបង្កើតសមាគម" មានន័យដូចម្តេច?<br>**ការវិភាគ** | **សេចក្តីសន្និដ្ឋាន**<br>សេចក្តីព្រាងច្បាប់នេះត្រូវតែ ស៊ីគ្នាជាមួយនឹងគោលបំណងរបស់ខ្លួន។ |

| | | | |
|---|---|---|---|
| | | ការការពារសិទ្ធិទទួលបានសេរីភាពក្នុងការបង្កើតសមាគម ត្រូវបានធានាដោយរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា និងឧបករណ៍គតិយុត្តអន្តរជាតិដទៃទៀត ដែលប្រទេសកម្ពុជាបានធ្វើសច្ចាប័ន ឬចូលជាសមាជិក។ មាត្រាដទៃទៀតនៃច្បាប់ស្ដីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល ត្រូវព្រាងឡើងដោយគិតទៅដល់កាតព្វកិច្ចរបស់ប្រទេសកម្ពុជា ដែលចែងនៅក្នុងរដ្ឋធម្មនុញ្ញនិងឧបករណ៍ទាំងនោះ។ ឧបករណ៍ទាំងនោះចែងពីសិទ្ធិ (មិនមែនសុទ្ធតែកាតព្វកិច្ច) របស់ពលរដ្ឋដើម្បីទទួលបានសិទ្ធិពលរដ្ឋនិងនយោបាយ។<br>បន្ទាប់ពីពិនិត្យសេចក្ដីព្រាងច្បាប់នោះមក គេមិនឃើញមានការចែងពីសិទ្ធិសំរាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលទេ លើកលែងតែសិទ្ធិទទួលបានការលើកលែងពន្ធដារលើប្រាក់ជំនួយ ដែលច្បាប់នេះនិយាយយោងទៅច្បាប់ពន្ធដារផ្សេងទៀត។ គេឃើញមានតែលក្ខខណ្ឌ និង បញ្ជីកាតព្វកិច្ចដ៏វែងមួយដែលដាក់លើសមាគមនិង អង្គការមិនមែនរដ្ឋាភិបាល។ | |
| ២ | ២ | **មាត្រា ២៖ ទំនាក់ទំនងរវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាមួយអាជ្ញធរសាធារណៈដើម្បីអភិវឌ្ឍសង្គម**<br>មាត្រានេះ ចង្អុលបង្ហាញអំពីវិសាលភាពនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីអភិវឌ្ឍសង្គម។ នេះហាក់ដូចជាកំណត់តែអំពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យអភិវឌ្ឍសេដ្ឋកិច្ចប៉ុណ្ណោះ។ | បង្កើន និងការពារសិទ្ធិមនុស្ស |
| ៣ | ៤ | **មាត្រា ៤៖និយមន័យ**<br>មាត្រា ៤៖ ផ្ដល់នូវភាពស្រពិលស្រពិលអំពីនិយមន័យ នៃសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសសំដៅលើ "ក្រុមរូបវន្តបុគ្គល ឬនីតិបុគ្គលបរទេស ដែលបង្កើតឡើងក្រោមច្បាប់បរទេស ក្នុងគោលបំណងធ្វើសកម្មភាពដើម្បីបម្រើផលប្រយោជន៍សមាជិករបស់ខ្លួន ឬធ្វើសកម្មភាពដើម្បីបម្រើប្រយោជន៍សាធារណៈដោយមិនទាញយកប្រាក់ចំណេញ ឬមិនយកកម្រៃមកចែកគ្នា"។<br>មាត្រានេះបានដកចេញនូវអង្គការសហគមន៍ និងវាហាក់ដូចជាច្បាមយកក្រុមនេះទៅជាអង្គភាពដែលកំណត់នៅក្នុងនិយមន័យ នៃសមាគម ដែលតម្រូវឲ្យមានការចុះបញ្ជី។ បន្ទុកសំខាន់នៃលក្ខខណ្ឌនៃការចុះបញ្ជីជាកំណត់ចំពោះក្រុមសហគមន៍ឬអង្គការមូលដ្ឋានអាចជះឥទ្ធិពលអាក្រក់ចំពោះសេរីភាពនៃការបង្កើតសមាគមន៍នៃក្រុមទាំងនេះ។ បន្ថែមពីលើនេះទៀត ការកំណត់និយមន័យមិនច្បាស់លាស់អាច | មាត្រា ៤ គួរត្រូវចែងឲ្យច្បាស់លាស់ដើម្បីអនុញ្ញាតឲ្យក្រុមជនដែលមិនមែនជាជនជាតិកម្ពុជាអាចបង្កើតសមាគម និងអង្គការក្នុងស្រុកបាន។ |

| | | | |
|---|---|---|---|
| | | នាំឲ្យមានវិធានរិតត្បិតលើការចុះបញ្ជី លើក្រុមនេះថាតើសកម្មភាពរបស់ពួកគេធ្វើដោយស្របច្បាប់ឬយ៉ាងណា ឧទាហរណ៍សកម្មជនដីធ្លីជាដើម។<br>វាបង្កើតនូវហានិភ័យមួយដែលអាជ្ញាធរអាចបកស្រាយបញ្ញត្តិនេះដោយរួមបញ្ចូលទាំងអង្គការសហគម៍មូលដ្ឋាន និងការប្រើខុសឬមិនយល់ស្របដើម្បីធ្វើការរិតត្បិតលើចលនាប្រជាពលរដ្ឋមូលដ្ឋាន។ | |
| ៤ | ៥ | **មាត្រា ៥៖ ការរឹតត្បិតទៅលើបុគ្គលដែលបានកាន់តំណែងដឹកនាំនៅក្នុងសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានលុបចេញពីបញ្ជី**<br>**ចំណោទ៖**<br>១. តើតំណែងអ្វីដែលត្រូវចាត់ទុកជា "តំណែងដឹកនាំ"?<br>២. តើការ "លុបឈ្មោះចេញពីបញ្ជី" មាននិយមន័យផ្លូវច្បាប់ដូចម្តេច?<br>៣. សូម្បីតែបុគ្គលដែលកាន់តំណែងនៅក្នុងសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីក្តី តើគេត្រូវហាមឃាត់បុគ្គលទាំងនោះមិនឲ្យបង្កើតសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលមួយទៀតដែរឬទេ?<br>មាត្រា៥ មានបញ្ហានៅក្នុងលំដាប់ជាច្រើន។ ទី១ បុគ្គលដែលត្រូវបានមាត្រានេះរិតត្បិតលើសេរីភាពនៃបង្កើតសមាគមមិនត្រូវបានកំណត់និយមន័យច្បាស់លាស់ទេ។ ទី២ មាត្រានេះគ្មានមូលដ្ឋានច្បាប់ដើម្បីចាត់ទុកថា អង្គការណាមួយត្រូវបានលុបចោលពីបញ្ជីថាជារឿងខុសច្បាប់នោះទេ។ ចំណុចចុងក្រោយ និងសំខាន់នោះគឺមាត្រានេះផ្ទុយនឹងច្បាប់ជាតិ និងច្បាប់អន្តរជាតិដែលទាក់ទងនឹងសិទ្ធិពលរដ្ឋ និងនយោបាយ។<br>**ក.យោងតាមក្របខណ្ឌគតិយុត្តកម្ពុជា**<br>**១.តំណែងដឹកនាំ**<br>សេចក្តីព្រាងច្បាប់នេះមិនបានឲ្យនិយមន័យនៃពាក្យ "បំពេញតួនាទីជាថ្នាក់ដឹកនាំ" ទេ។ ការខ្វះខាតនិយមន័យនេះ នាំឲ្យមានការបកស្រាយស្រេចតែចិត្ត ដើម្បីរឹតត្បិតសេរីភាពក្នុងការបង្កើតសមាគម។ ឧទាហរណ៍ ការរឹតត្បិតអាចធ្វើលើតំណែងថ្នាក់ខ្ពស់ ថ្នាក់មធ្យមក៏បាន។<br>**២.លុបឈ្មោះចេញពីបញ្ជី** | គួរកែប្រែមាត្រានេះឲ្យស្របតាមលក្ខខណ្ឌដែលមានកំណត់នៅក្នុងវិធានអន្តរជាតិដែលទាក់ទងនឹងសេរីភាពនៃសមាគម។ ម្យ៉ាងទៀតគួរធ្វើការកែប្រែមាត្រា៥ ដើម្បីលុបលក្ខខណ្ឌអំពីសមាជិកស្ថាបនិកដែលគ្មានភាពជាអ្នកដឹកនាំនៅក្នុងសមាគម ឬអង្គការក្នុងស្រុក។ និយាមអន្តរជាតិដែលចែងពីចំនួនមនុស្សដែលអាចបង្កើតសមាគមបាន គឺ ២ នាក់ឡើងទៅ។ |

ច្បាប់នេះចាត់ទុកយ៉ាងជាក់ស្តែងអង្គការដែលត្រូវបានលុបឈ្មោះពីបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលថាជាអង្គការខុសច្បាប់ ហើយ ដូច្នេះ អ្នកដឹកនាំអង្គការទាំងនោះគ្មានសិទ្ធិបង្កើតសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលទៀតទេ។

ការដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលមួយត្រូវបានលុបឈ្មោះចេញពីបញ្ជីមិនមែនមានន័យថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះខុសច្បាប់ទេ។ មានវិធីច្រើនយ៉ាងក្នុងការបញ្ចប់អត្ថិភាពនៃនីតិបុគ្គល យោងតាមក្រម រដ្ឋប្បវេណី (មាត្រា ៦៤)៖

ក.ការរំលាយដោយសារការកើតឡើងនូវព្រឹត្តិការណ៍នៃការរំលាយ ដែលបញ្ជាក់នៅក្នុងលក្ខន្តិកៈនៃនីតិបុគ្គល

ខ.បេសកកម្ម ឬ កម្មវត្ថុ ដែលនីតិបុគ្គលនោះត្រូវបានបង្កើត ត្រូវបានបំពេញចប់សព្វគ្រប់

គ.ក្ស័យធន

ឃ.ការរំលាយដោយដីកា ឬ សាលក្រមតុលាការ

ង.ការរំលាយដោយមហាសន្និបាតនៃសមាជិក

ច.នីតិបុគ្គលនៅសល់សមាជិកតែម្នាក់។

ក្នុងចំណោមលក្ខណៈវិនិច្ឆ័យនៃការរំលាយទាំងនេះ មានតែលក្ខណៈវិនិច្ឆ័យមួយគត់ដែលទាក់ទងនឹងការដាក់ទណ្ឌកម្មដោយតុលាការ ដែលអាចប្រកាសអនីត្យានុកូលភាព (ភាពខុសច្បាប់) ឬ ភាពមិនពេញច្បាប់នៃនីតិបុគ្គល។ លក្ខណៈវិនិច្ឆ័យដទៃទៀតទាក់ទងនឹងការរំលាយដោយស្ម័គ្រចិត្តប៉ុណ្ណោះ។

ដូច្នេះ ច្បាប់នេះគ្មានមូលដ្ឋានគតិយុត្ត (មូលដ្ឋានច្បាប់) ដើម្បីចាត់ទុកថាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវលុបឈ្មោះជានីតិបុគ្គលខុសច្បាប់ទេ។ សូម្បីតែតុលាការប្រកាសរំលាយនីតិបុគ្គលក្តី ក៏ការរំលាយមួយនោះមិនមែនកើតឡើងដោយសារសកម្មភាពខុសច្បាប់របស់នីតិបុគ្គលនោះដែរ។ ឧទាហរណ៍ ការរំលាយអាចកើតចេញពី "ការលំបាកក្នុងការអនុវត្តការងារ" (មាត្រា ៦៥.២.ក)។

សូម្បីតែមានការប្រកាសអនីត្យានុកូល ឬភាពមិនពេញច្បាប់នៃនីតិបុគ្គលក៏ដោយ ក៏វាមិនមានន័យជាចាំបាច់ថាមនុស្សដែលធ្វើការឲ្យនីតិបុគ្គលនោះមានពិរុទ្ធភាពដែរ។

**៣. បុគ្គលដែលកាន់តួនាទីដឹកនាំនៅក្នុងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវលុបឈ្មោះ គ្មានសិទ្ធិបង្កើតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលថ្មី**

សិទ្ធិដើម្បីបង្កើតសមាគម គឺជាសិទ្ធិដែលប្រទានដោយរដ្ឋធម្មនុញ្ញកម្ពុជា (មាត្រា ៤២) និងឧបករណ៍អន្តរជាតិដទៃទៀតដែលកម្ពុជាបានធ្វើសច្ចាប័ន (ឧទាហរណ៍ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ មាត្រា ២២)។

នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ការដកហូតសិទ្ធិពលរដ្ឋអាចធ្វើបានតែក្នុងករណីដែលមានការប្រកាសសាលក្រមរបស់តុលាការតែប៉ុណ្ណោះ ដោយសារការផ្តន្ទាទោសចំបង (មូលទោស) ឧទាហរណ៍ មានទោសពីបទរំលោភសេចក្តីទុកចិត្ត[1]។ ការដកហូតសិទ្ធិពលរដ្ឋគឺជាការដាក់ទោសបន្ថែមទោះលើមូលទោស (មាត្រា ៥៣.១ ក្រមព្រហ្មទណ្ឌ)។ មានកាលៈទេសៈដែលមនុស្សម្នាក់អាចត្រូវដកហូតសិទ្ធិពលរដ្ឋរបស់គេ ហើយក្នុងនោះ គ្មានកាលៈទេសៈណាមួយដែលអនុវត្តចំពោះសិទ្ធិនិងសេរីភាពក្នុងការបង្កើតសមាគមឡើយ។ មានសិទ្ធិពលរដ្ឋមួយចំនួនដែលតុលាការអាចដកហូតពីជនជាប់ចោទ។ សិទ្ធិពលរដ្ឋទាំងនោះមាន (មាត្រា ៥៥ ក្រមព្រហ្មទណ្ឌ)៖

- សិទ្ធិបោះឆ្នោត
- សិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត
- សិទ្ធិកាន់តំណែងមុខងារសាធារណៈ
- សិទ្ធិទទួលការតែងតាំងជាអ្នកជំនាញ, មជ្ឈត្តករ, ឬ អាណត្តិគាហកដែលតែងតាំងដោយតុលាការ
- សិទ្ធិទទួលគ្រឿងឥស្សរិយយស
- សិទ្ធិធ្វើជាសាក្សីនៅក្នុងតុលាការ

ថែមលើការដកហូតសិទ្ធិពលរដ្ឋ អាចមានការដកហូតសេរីភាពក្នុងការប្រកបវិជ្ជាជីវៈណាមួយដោយសារការផ្តន្ទាទោសចំបងនៅក្នុងពេល និងទាក់ទងទៅនឹងការប្រកបវិជ្ជាជីវៈនោះ (មាត្រា ៥៦ ក្រមព្រហ្មទណ្ឌ)។ ឧទាហរណ៍ បើវេជ្ជបណ្ឌិតម្នាក់ប្រព្រឹត្តបទល្មើសរំលោភបំពានកេរ្តិ៍ខ្មាស់របស់អ្នកជម្ងឺ ហើយ

---

[1] នៅក្នុងបទរំលោភសេចក្តីទុកចិត្ត នាយក ឬអ្នកគ្រប់គ្រងដែលត្រូវផ្តន្ទាទោសពីបទនេះ អាច (ប៉ុន្តែមិនមែនត្រូវតែ) ត្រូវបានដកហូតសិទ្ធិពលរដ្ឋខ្លះពីការប្រកបវិជ្ជាជីវៈណាមួយ (មាត្រា ៣៩៣.៣៩៦)។

ចៅក្រមអាចដាក់ទោសបន្ថែមមិនឲ្យធ្វើពេទ្យចំនួន ៥ ឆ្នាំ។ នៅក្នុងកាលៈទេសៈនេះ គ្មានការហាមឃាត់ណាអាចធ្វើបានចំពោះការព្យាយាមរបស់វេជ្ជបណ្ឌិតនោះដើម្បីបើកសមាគមដើម្បីលើកស្ទួយការថែទាំសុខភាពទេ។

ចៅក្រមអាចដាក់ទោសបន្ថែមតែចំនួនច្រើនបំផុត ៥ ឆ្នាំ។ បន្ទាប់ពី ៥ ឆ្នាំទៅ សិទ្ធិពលរដ្ឋរបស់ទណ្ឌិតនឹងត្រូវស្តារឡើងវិញជាស្វ័យប្រវត្តិ។

ផ្អែកលើការវិភាគខាងលើ សិទ្ធិបង្កើតសមាគមមិនត្រូវបានដាក់បញ្ចូលនៅក្នុងបញ្ជីសិទ្ធិពលរដ្ឋដែលតុលាការអាចដកហូតទេ។ ការដកហូតសេរីភាពក្នុងការប្រកបវិជ្ជាជីវៈណាមួយ មិនមែនមានន័យចាំបាច់ថានឹងនាំឲ្យបាត់បង់សេរីភាពក្នុងការបង្កើតសមាគមទេ។

**ខ. យោងតាមក្របខណ្ឌគតិយុត្តអន្តរជាតិ**

មាត្រា ២២ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ចែងថាមនុស្សរាល់រូបមានសិទ្ធិទទួលបានសេរីភាពក្នុងការបង្កើតសមាគមជាមួយអ្នកដទៃ ហើយការរឹតត្បិតលើការអនុវត្តសិទ្ធិនេះអាចធ្វើទៅបានតែក្នុងករណីដែលមានចែងដោយច្បាប់ ហើយក្នុងពេលណាដែលជាការ "ចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬ សុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈ ឬ សីលធម៌ ឬ ការការពារសិទ្ធិនិងសេរីភាពរបស់អ្នកដទៃ"។

ជាការច្បាស់ណាស់ តាមមាត្រា ២២ ខាងលើនេះ គ្មានលក្ខណៈវិនិច្ឆ័យណាមួយដែលអាចយកមកអនុវត្តបានដើម្បីរឹតត្បិតមនុស្សម្នាក់មិនឲ្យបង្កើតសមាគម ព្រោះមកពីសមាជិកភាពរបស់គាត់នៅក្នុងអង្គការមួយដែលត្រូវលុបចេញពីបញ្ជីនោះទេ។ ច្បាប់ដែលរឹតត្បិតមនុស្សម្នាក់មិនឲ្យអនុវត្តសិទ្ធិរបស់គេដើម្បីបង្កើតសមាគម ជាច្បាប់ដែលគ្មានយុត្តិកម្មដើម្បីបំពេញតាមសេចក្តីតម្រូវនៃការរឹតត្បិតក្រោមមាត្រា ២២ នៃកតិកាសញ្ញា។ មនុស្សម្នាក់ ដែលនៅក្នុងអង្គការដែលត្រូវបានលុបឈ្មោះ គ្មានអ្វីទាក់ទងជាមួយការធ្វើឲ្យគ្រោះថ្នាក់ដល់សន្តិសុខជាតិ ឬ សុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់ ការការពារសុខភាពសាធារណៈ ឬ សីលធម៌ទេ ប្រសិនបើគាត់មិនត្រូវបានប្រកាសទោសដោយតុលាការទាក់ទងនឹងរឿងនេះ។

មាត្រា២១(១)នៃសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្សចែងថា "គ្រប់បុគ្គលទាំងអស់មានសិទ្ធិ និងសេរីភាពទាំងអស់ដែលមានកំណត់នៅក្នុងសេចក្តីថ្លែងការណ៍នេះ ដោយគ្មានការបែងចែកពណ៌សម្បុរអ្វីឡើយ..." នៅក្នុងមាត្រា២ (១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយក៏មាន

| | | | |
|---|---|---|---|
| | | ចង្អុលបង្ហាញពីចំណុចនេះដែរ ដោយមានបញ្ជាក់យ៉ាងច្បាស់ថា សិទ្ធិដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយមានវិសាលភាព "លើបុគ្គលគ្រប់រូបទាំងអស់នៅក្នុងដែនដីរដ្ឋ និងអនុលោមតាមយុត្តាធិការរបស់ខ្លួន"។ គណកម្មាធិការសិទ្ធិមនុស្សនៃកតិកាសញ្ញាសិទ្ធិពលរដ្ឋ និងនយោបាយនៅក្នុងបទអត្ថាធិប្បាយទូទៅលេខ១៥បានពន្យល់ថា សិទ្ធិដែលមានចែងនៅក្នុងកតិកាសញ្ញាអនុវត្តលើគ្រប់បុគ្គលម្នាក់ៗ ដោយមិនគិតពីការផ្លាស់ និងប្តូរសញ្ជាតិ ឬអ្នកដែលគ្មានរដ្ឋនោះទេ" ហើយដែល "ជនបរទេសក៏ទទួលបាននូវផលប្រយោជន៍នៃសទ្ធិនោះ.....សេរីភាពការបង្កើតសមាគម"។<br>មាត្រា៥ តម្រូវឲ្យសមាជិកស្ថាបនិកពលរដ្ឋកម្ពុជា៥នាក់ដែលមានអាយុចាប់ពី១៨ឆ្នាំឡើងទៅដើម្បីបង្កើតសមាគម ឬអង្គការដែលមាត្រានេះរិតត្បិតដល់អនីតិជនក្នុងការបង្កើតសមាគមរបស់ខ្លួន។ មាត្រានេះផ្ទុយទៅនឹងមាត្រា១៥នៃកតិកាសញ្ញ អន្តរជាតិស្តីពីសិទ្ធិកុមារដែលតម្រូវឲ្យរដ្ឋជាភាគីត្រូវ "ទទួលស្គាល់សិទ្ធិកុមារលើសេរីភាពនៃបង្កើតសមាគម និងសេរីភាពនៃការជួបជុំដោយសន្តិវិធី" ហើយការរិតត្បិតលើសេរីភាពនេះ "អាចធ្វើទៅបានលុះត្រាតែស្របច្បាប់ និងដែលមានភាពចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យក្នុងបុព្វហេតុទាក់ទងនឹងសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាព ឬសីលធម៌សាធារណៈ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ"។[2]<br>មាត្រា៥កំណត់អំពីសមាជិស្ថាបនិកដែលបុគ្គលទាំងនោះនឹងមិនត្រូវមានតួនាទីជាថ្នាក់ដឹកនាំនៅក្នុងសមាគម ឬអង្គការមិនមែនរដ្ឋភិបាលក្នុងស្រុកដែល "ត្រូវបានលុបឈ្មោះ"ឡើយ។ សមាគម និងអង្គមិនមែនរដ្ឋាភិបាលក្នុងស្រុកអាចត្រូវបានលុបឈ្មោះចេញពីបញ្ជីដោយមូលហេតុផ្សេងៗរួមទាំងមូលហេតុមិនច្បាស់លាស់ និងមូលហេតុតាមអំពើចិត្ត។ បន្ថែមពីលើនេះទៀត អង្គការដែលអាចសុំបញ្ឈប់បេសកម្មរបស់ខ្លួនដោយស្ម័គ្រចិត្តដោយមូលហេតុចប់បេសកម្មអាចជាកម្មវត្ថុនៅក្នុងការរិតត្បិតនេះដែរ។ វាលែងតែ ថ្នាក់ដឹកនាំអង្គការមុនដែលត្រូវបានដកចេញពីបញ្ជី មិនគួរត្រូវបានបាត់បង់សិទ្ធិជាមូលដ្ឋាននៃសេរីភាពនៃការបង្កើតសមាគមឡើយ។<br>**មាត្រា ៥៖ ចំនួនអ្នករៀបចំបង្កើតសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល**<br>**ចំណោទ** | |

[2] កម្ពុជាបានផ្តល់សច្ចាប័នលើកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារឆ្នាំ១៩៩២

| | | | |
|---|---|---|---|
| | | តើការកំណត់ចំនួនមនុស្សដែលអាចបង្កើតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលជាការស្របច្បាប់ដែរឬទេ?<br>**ការវិភាគ**<br>សេចក្ដីព្រាងច្បាប់នេះតម្រូវថា ដើម្បីបង្កើតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបាន គេត្រូវមានមនុស្សយ៉ាងតិចណាស់ ៥ នាក់។ ថ្វីបើការតម្រូវបែបនេះ មិនជាការតឹងរឹងប៉ុន្មានដល់សេរីភាពនៃការបង្កើតសមាគម ការតម្រូវបែបនេះជាការមិនស្របនឹងសភាពជាក់ស្ដែង ពីព្រោះវាដកហូតនូវសិទ្ធិនៃមនុស្សចំនួនតិចជាងដើម្បីបង្កើតសមាគម។ ឧទាហរណ៍ នៅក្នុងដំណាក់ការដំបូង សមាគមមួយអាចត្រូវបង្កើតឡើងដោយស្ថាបនិកពីរនាក់ និងក្រោយមកសមាជិកភាពនៃសមាគមត្រូវបានពង្រីកឲ្យក្លាយជាសមាគមមួយធំជាង។ វាគ្មានមូលដ្ឋានផ្លូវច្បាប់អ្វីដែលថា ហេតុអ្វីបានជាមនុស្ស ២, ៣, ឬ ៤ នាក់មិនអាចបង្កើតសមាគមបាន ដូចជាក្នុងករណីសមាគមពាណិជ្ជកម្ម (សូមមើលច្បាប់ស្ដីពីសហគ្រាសពាណិជ្ជកម្ម)។ | |
| ៥ | ៦ | **មាត្រា ៦៖ សំណុំលិខិតនៃការចុះបញ្ជី**<br>***ឯកសារតម្រូវ:*** មាត្រា ៦ តម្រូវឲ្យអ្នកដាក់ពាក្យសុំចុះបញ្ជីត្រូវដាក់នូវ "ជីវប្រវត្តិរបស់ស្ថាបនិកម្នាក់ៗដោយមានបិតរូបថត ទំហំ៤គុណ៦"។ ពាក្យ "ជីវប្រវត្តិ"មិនត្រូវបានកំណត់និយមន័យទេ ហើយអាចនាំអោយរដ្ឋាភិបាលសួររកហេតុមិនចេះចប់លើប្រវត្តិរូបរបស់ស្ថាបនិកទាំងនោះ។ *បុគ្គលនីមួយៗ* មានសិទ្ធិក្នុងការបង្កើតសមាគម ហើយ "អាជ្ញាធរត្រូវ ….គោរពសិទ្ធិ បង្កើតសមាគមដោយឯកជនភាពដូចមានកំណត់នៅក្នុងមាត្រា ១៧នៃកតិកាសញ្ញាសិទ្ធិពលរដ្ឋ និងនយោបាយ។[3] ការ ដាក់ "ជីវប្រវត្តិរបស់ស្ថាបនិកម្នាក់ៗ" អាចធ្វើឲ្យរដ្ឋាភិបាលពិនិត្យមើលលើជីវប្រវត្តិស្ថាបនិកទាំងនោះដើម្បីធ្វើសេចក្ដីសម្រេចលើការសុំបង្កើតអង្គការស្របច្បាប់ឬអត់។ ចំណុចជាបញ្ហានោះគឺថា ខ្វះការស្ដង់ដារ ឬមាត្រដ្ឋានក្នុងការបដិសេធមិនចុះបញ្ជី ឲ្យ នេះជាផលវិបាកនៃការដាក់ជីវប្រវត្តិស្ថាបនិកដែលអាចនាំឲ្យការសេចក្ដីសម្រេចរបស់រដ្ឋាភិបាលដូចសេះដាច់បង្ហៀរ។<br>***ការចុះបញ្ជីការិយាល័យ:*** មាត្រា ៦ តម្រូវឲ្យសមាគម ឬអង្គការក្នុងស្រុកមានការិយាល័យនៅក្នុងប្រទេសកម្ពុជា។ នៅប្រទេសផ្សេងទៀត តម្រូវឲ្យអង្គការផ្ដល់តែអាសយដ្ឋាន តម្រូវការដើម្បីធានានូវទីធ្លាមាន | គួរកែតម្រូវលក្ខខណ្ឌដែលមានកំណត់នៅក្នុងមាត្រា៦នេះលើករណីនៃសមាជិកស្ថាបនិក។ លុបចោលនៅលក្ខខណ្ឌមិនច្បាស់លាស់លើ "ជីវប្រវត្តិ" ហើយផ្ដល់នូវលក្ខខណ្ឌងាយស្រួលមួយលើឈ្មោះ និងអាសយដ្ឋាន ដោយសម្រូវតែអ្នកដាក់ពាក្យ មានតែអាសយដ្ឋានមួយជាការគ្រប់គ្រាន់ ដោយមិនតម្រូវឲ្យមានទីស្នាក់កណ្ដាលឡើយ។<br>មាត្រា៦នេះគួរដូរពីឃ្លា "អាសយដ្ឋានរបស់សមាគមន ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក" ទៅជា |

[3] របាយការណ៍អ្នកតំណាងពិសេសរបស់អង្គការសហប្រជាជាតិស្ដីពីសេរីភាពការជួបជុំដោយសន្តិវិធី និងសេរីភាពនៃការបង្កើតសមាគម Maina Kiai, para.65, U.N.Doc. A/HRC/20/27 (21 May 2012)

| | | | |
|---|---|---|---|
| | | សុវត្ថិភាពពិតប្រាកដគឺមានលក្ខណៈសំខាន់ហើយស្មុគ្រស្មាញច្រើន។ ទីស្នាក់ការកណ្តាលអាចជាទីតាំងដែលមានភាពងាយស្រួលសម្រាប់អង្គការដែរលមានមូលនិធិច្រើន ប៉ុន្តែសមាគមសហគមន៍មូលដ្ឋាន និងអង្គការតូចៗអាចធ្វើការងារដោយសាមញ្ញនៅក្នុងសហគមន៍ ធ្វើការប្រជុំ នៅផ្ទះសមាជិកណាមួយ ដោយមិនចាំបាច់ឲ្យមានទីស្នាក់ការកណ្តាលឡើយ។ បន្ថែមពីលើនេះទៀត បើការចុះបញ្ជីទាមទារ ឲ្យអ្នកដាក់ពាក្យនោះត្រូវដាក់ "លិខិតដែលមានបញ្ជាក់អំពីទីស្នាក់ការកណ្តាលជាអាទីដែលត្រូវមានការបញ្ជាក់ពីមេឃុំឬចៅសង្កាត"។ លក្ខខណ្ឌដើម្បីដាក់លិខិតទាំងនេះគឺមិនចាំបាច់ត្រូវមានការិយាធិបតេយ្យនៅក្នុងដំណើរការនៃការចុះបញ្ជីដែលអាចទំនងជាហេតុធ្វើឲ្យពន្យាដល់ការចុះបញ្ជី។ | អាសយដ្ឋានរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកគួរដាក់បញ្ចូលនៅក្នុងផ្នែកនៃពាក្យសុំចុះបញ្ជី។ ឧទាហរណ៍ មាត្រា៦ កថាខណ្ឌ១ចែងថា "ពាក្យសុំចុះបញ្ជាក់មានពីរច្បាប់ដែលនោះក្នុងពាក្យសុំនោះត្រូវសរសេរអំពីអាសយដ្ឋាននៃសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក"។ មាត្រា៦ កថាខណ្ឌ៣ មិនគួរដាក់ "ប្រវត្តិរូប" ឬ"ជីវប្រវត្ត"នៃសាមាជិកស្ថាបនិកឡើយ។ កថាខណ្ឌ៣នេះគួសរសេរថា " ឈ្មោះ និងអាសយដ្ឋានមានពីរច្បាប់ចំពោះសមាជិកស្ថាបនិកនីមួយៗ"។ |
| ៦ | ៧ | **មាត្រា ៧៖ ពត៌មានដែលត្រូវចុះក្នុងលក្ខន្តិកៈ**<br>ពត៌មានដែលតម្រូវឲ្យចុះនៅក្នុងលក្ខន្តិកៈ មិនបានគិតពីតួនាទីរបស់ក្រុមប្រឹក្សាភិបាលទេ។ ដើម្បីលើកស្ទួយដល់អភិបាលកិច្ចឲ្យបានប្រសើរ ពត៌មានអប្បបរមាគួរបញ្ចូលតួនាទីរបស់ក្រុមប្រឹក្សាភិបាលផងដែរ។ | |
| ៧ | ៨ | **មាត្រា ៨៖ លក្ខណៈវិនិច្ឆ័យសំរាប់ការយល់ព្រមចុះបញ្ជី**<br>**ចំណោទ**<br>១.តើអ្វីជាលក្ខណៈវិនិច្ឆ័យនៃការបដិសេធការចុះបញ្ជី?<br>២.ទោះបីគ្មានការឆ្លើយតបរបស់ក្រសួងមហាផ្ទៃអាចចាត់ទុកជាការយល់ព្រមចុះបញ្ជីក្តី តើសមាគមអាចដំណើរការបានដែរឬទេ តាមការជាក់ស្តែង? | មាត្រា៨នេះគួរកែប្រែដោយចែងឲ្យមានការការពារសមស្របសម្រាប់អ្នកដាក់ពាក្យចុះបញ្ជី រួមបញ្ចូលទាំងភាពច្បាស់លាស់ និងការកម្រិតបញ្ជីមូលដ្ឋាននៃកម្មវត្ថុលើការបដិសេធនៃការចុះបញ្ជី។ |

៣.តើការតវ៉ានៅតុលាការជាការមានប្រយោជន៍ជាក់ស្តែងសម្រាប់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបង្កើតថ្មីដែរឬទេ?

**ការវិភាគ**

**១.លក្ខណៈវិនិច្ឆ័យសម្រាប់ការបដិសេធការចុះបញ្ជី**

ក្រសួងមហាផ្ទៃ "ធ្វើការពិនិត្យលើឯកសារ និងភាពស្របច្បាប់នៃលក្ខន្តិកៈ" ហើយសម្រេច "ថាតើគួរទទួល ឬបដិសេធចុះបញ្ជី" ឲ្យអង្គភាពនោះ។ វាមិនមានភាពច្បាស់លាស់ទេ ប្រសិនបើ ស្តង់ដា "ភាពស្របច្បាប់" មានចេតនាក្នុងកំណត់នូវឆន្ទានុសិទ្ធិរបស់រដ្ឋាភិបាលក្នុងសម្រេចថាតើទទួល ឬមិនទទួលចុះបញ្ជី មាត្រានេះមិនបានបង្ហាញច្បាស់លាស់ឡើយអំពីមូលដ្ឋាននៃបដិសេធនៃការចុះបញ្ជី។ ទោះបីបើ "ភាពស្របច្បាប់"ដែលមានចេតនាដូចលក្ខខណ្ឌតែម្យ៉ាងក្នុងការ បដិសេធដែលមិនស្របទៅនឹងបទបញ្ញត្តិច្បាប់ផ្សេងៗទៀតថាតើវាស្របនៅទឹងច្បាប់អន្តរជាតិឬអត់។

មាត្រា ៨ ក៏ចែងផងដែរថា ក្រសួងមហាផ្ទៃអាចបដិសេធការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល បើខ្លួនមើលឃើញថាគោលបំណងនិងទិសដៅ (មាត្រា ៧.១) នៃសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលចង់បង្កើតនោះ<u>អាច</u> ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កឲ្យអន្តរាយដល់សន្តិសុខជាតិ វប្បធម៌ ប្រពៃណី និងទំនៀមទំលាប់របស់សង្គមជាតិកម្ពុជា។

សេចក្តីព្រាងនេះប្រើប្រាស់វិធីពិនិត្យមើលតាមបែបមិនជាក់ស្តែង ដែលមានន័យថាអ្នកពិនិត្យមើលទៅលើពាក្យពេចន៍ដែលគេសរសេរនៅក្នុង គោលបំណងនិងទិសដៅនៃលក្ខន្តិកៈ ហើយបកស្រាយពាក្យពេចន៍ទាំងនោះ ថាពាក្យពេចន៍ទាំងនោះមានន័យចំៗ ឬ មានន័យតុណ្ហិ ថាមានបំណងធ្វើឲ្យប៉ះពាល់ដល់ "សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កឲ្យអន្តរាយដល់សន្តិសុខជាតិ វប្បធម៌ ប្រពៃណី និងទំនៀមទំលាប់របស់សង្គមជាតិកម្ពុជា" ដែរឬទេ។

ការពិនិត្យមើលតាមបែបមិនជាក់ស្តែង អាចពាក់ព័ន្ធនឹងការទាយស្មាន។ ឧទាហរណ៍ បើលក្ខន្តិកៈចែងថា គោលបំណង និងទិសដៅនៃសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ដែលបម្រុងនឹងបង្កើតនោះគាំទ្រដល់សកម្មភាពប្រឆាំងនឹងដីសម្បទានសេដ្ឋកិច្ចខុសច្បាប់ នោះអ្នកពិនិត្យអាចបកស្រាយថា គោលបំណងនិងទិសដៅរបស់សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលនោះ ថាចង់កក្កូរកកាយភាពស្ងប់ស្ងាត់របស់សហគមន៍ និងធ្វើឲ្យខូច "សណ្តាប់ធ្នាប់សាធារណៈ" "សន្តិសុខ និង សុវត្ថិភាពសាធារណៈ" រួចហើយ

| | | | |
|---|---|---|---|
| | | បដិសេធការចុះបញ្ជីតែម្តង ទោះបីសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលដែលបម្រុងនឹងបង្កើតនោះ នឹងធ្វើតែសកម្មភាពអប់រំឲ្យយល់ដឹងពីដីសម្បទានសេដ្ឋកិច្ចក៏ដោយ។<br>តាមរបៀបនេះ អ្នកពិនិត្យមិនធ្វើជាអ្នកចុះបញ្ជីទេ តែជាអ្នកបកស្រាយច្បាប់ ដែលជាការងាររបស់ចៅក្រម។ អង្គការមិនមែនរដ្ឋាភិបាលខ្មែរ ជាពិសេសអង្គការសិទ្ធិមនុស្ស បានចៀសវាងពាក្យពេចន៍ទាំងឡាយ នៅក្នុងលក្ខន្តិកៈ ដែលគេគិតថាជា ពាក្យពេចន៍ដែលរសើបដល់រដ្ឋាភិបាល ដើម្បីចៀសវាងកុំឲ្យរដ្ឋាភិបាលបដិសេធ ឬ រករឿងការចុះបញ្ជីរបស់គេ។ ទោះបីគេអាចច្នៃរកពាក្យពេចន៍ដ៏សមស្របដើម្បីឲ្យគេចុះបញ្ជីឲ្យក៏ដោយ គេអាចធ្លាក់ចូលក្នុងអន្ទាក់មួយទៀត កាលណាសកម្មភាពពិតមិនស៊ីគ្នាទាំងស្រុងជាមួយពាក្យពេចន៍ដែលគេសរសេរនៅក្នុងគោលបំណងនិងទិសដៅនៃលក្ខន្តិកៈ។ រដ្ឋាភិបាលអាចបញ្ឈប់សកម្មភាព ពី ព្រោះ សកម្មភាព នោះ មិនស៊ីគ្នាជាមួយអ្វីដែលនិយាយនៅក្នុងលក្ខន្តិកៈ ទោះបីសកម្មភាពនោះមិនខុសច្បាប់ ក៏ដោយ។<br>មែនទែនទៅ សេចក្តីព្រាងច្បាប់នេះអាចយកលក្ខណៈវិនិច្ឆ័យនៃការរឹតត្បិតដែលអាចអនុញ្ញាតឲ្យបានស្របតាមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ ដើម្បីធ្វើយុត្តិកម្មការរឹតត្បិតដែលចែងក្នុងមាត្រា ៨ នៃសេចក្តីព្រាងច្បាប់នេះ។ ប៉ុន្តែ បទពិសោធន៍ បានបង្ហាញថា ពាក្យ "សន្តិសុខជាតិ ឬ សង្គម" "សុវត្ថិភាព" "សណ្តាប់ធ្នាប់សាធារណៈ" "ប្រពៃណី" "ទំនៀមទំលាប់" ត្រូវបានប្រើប្រាស់ដោយបំពានប្រឆាំងនឹងសេរីភាពក្នុងការនិយាយ។ ពាក្យទាំងនេះអាចយកមកបកស្រាយឲ្យមានន័យជាអ្វីក៏បាន រាប់ចាប់តាំងពីការពង្រាយសំរាមនៅទីកន្លែងណាមួយ រហូតដល់ទៅការធ្វើឲ្យរាំងស្ទះចរាចរណ៍។ល។<br>នៅក្នុងសេចក្តីអធិប្បាយលេខ ៣៤ របស់ខ្លួន គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ជាការឆ្លើយតបនឹងការបកស្រាយដោយបំពាននូវពាក្យ "សណ្តាប់ធ្នាប់សាធារណៈ" "សន្តិសុខជាតិ" ឬ "សីលធម៌" បានផ្តល់អនុសាសន៍ដល់រដ្ឋជាភាគីថា "ការរឹតត្បិតមិនត្រូវទូលំទូលាយ" (កថាខណ្ឌ ៣៤) ហើយថា ច្បាប់ "ត្រូវប្រើពាក្យដោយមានន័យជាក់ៗ ដើម្បីឲ្យបុគ្គលម្នាក់អាចសម្របអាកប្បកិរិយារបស់គេស្របទៅតាមពាក្យនោះ ហើយច្បាប់នោះត្រូវតែធ្វើឲ្យសាធារណជនងាយមើលនិងងាយយល់បាន"។ ដូច្នេះ ការយកពាក្យ "សណ្តាប់ធ្នាប់សាធារណៈ" "សន្តិសុខជាតិ"។ល។ មកធ្វើជាលក្ខណៈវិនិច្ឆ័យសំរាប់ការចុះបញ្ជី គឺជាការប្រឆាំងនឹងស្មារតីរបស់មាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ ហើយនឹងធ្វើឲ្យរលំរលាយដល់សិទ្ធិជាមូលដ្ឋានក្នុងការបង្កើតសមាគម។ | |

**សេចក្ដីសន្និដ្ឋាន**

ដោយហេតុថា ពាក្យទាំងនេះមានន័យទូលំទូលាយពេក ហើយត្រូវមើលនៅក្នុងបរិបទ និងត្រូវផ្អែកលើអង្គហេតុ (មិនមែនមានតែនៅលើក្រដាស) ពាក្យទាំងនេះត្រូវទុកឲ្យតុលាការជាអ្នកបកស្រាយ ជាជាងអ្នកចុះបញ្ជីបកស្រាយ។

ការពិនិត្យមើលតែលើឯកសារជាការគ្រប់គ្រាន់។ នេះមានន័យថា អ្នកចុះបញ្ជីត្រូវធ្វើសេចក្ដីសម្រេចចុះបញ្ជី ដោយផ្អែកតែលើភាពពេញលេញនៃឯកសារតែប៉ុណ្ណោះ។

**២. ការចុះបញ្ជីតាមព្រឹត្តិន័យ**

មាត្រា ៨ នៃសេចក្ដីព្រាងច្បាប់ចែងថា បើបន្ទាប់ពី ៤៥ ថ្ងៃនៃថ្ងៃធ្វើការទៅ ហើយក្រសួងមិនបានសំរេចពីការចុះបញ្ជីទេនោះ នោះសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលដែលបម្រុងនឹងបង្កើតនោះត្រូវចាត់ទុកថាត្រូវបានចុះបញ្ជីជាស្វ័យប្រវត្តិ។ សេកចក្ដីព្រាងនេះមិនបានចែងបញ្ជាក់ឲ្យច្បាស់ថា តើក្រសួងត្រូវចេញវិញ្ញាបនប័ត្រចុះបញ្ជីដែរឬអត់ ឬសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលអាចធ្វើសកម្មភាពដោយសេរី។

ទោះបីសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលអាចធ្វើសកម្មភាពដោយសេរី ដោយសារក្រសួងមិនបានឆ្លើយតបនឹងការដាក់ពាក្យសុំចុះបញ្ជី សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលនឹងប្រឈមមុខនឹងការជាក់ស្ដែង ដោយសារសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលគ្មានអត្តសញ្ញាណតាមផ្លូវច្បាប់។ ច្បាប់ខ្លះតម្រូវឲ្យមានការបង្ហាញនូវអត្តសញ្ញាណផ្លូវច្បាប់ ដើម្បីឲ្យអង្គការមួយអាចធ្វើកិច្ចការជាមួយអ្នកដទៃ។ ឧទាហរណ៍ អង្គភាពមួយមិនអាចបើកគណនីធនាគារដោយគ្មានវិញ្ញាបនប័ត្រចុះបញ្ជី មិនអាចចុះបញ្ជីពន្ធដារ មិនអាចទិញដីជាដើម។ល។ យ៉ាប់ជាងនេះទៅទៀតគឺ អាជ្ញាធរមូលដ្ឋានអាចសួររកភស្តុតាងនៃការចុះបញ្ជី ដើម្បីបញ្ជាក់ឲ្យឃើញថា អង្គការមួយមានអត្ថិភាព និងដើម្បីអនុញ្ញាតឲ្យធ្វើសកម្មភាព (ព្រោះច្បាប់នេះមិនឲ្យធ្វើសកម្មភាព បើមិនចុះបញ្ជី)។ មួយទៀត អង្គការមួយមិនអាចទទួលជំនួយពីម្ចាស់ជំនួយ បើគ្មានវិញ្ញាបនប័ត្រចុះបញ្ជី។

រឿងនេះអាចជាការបន្ទាប់បន្សំ ប៉ុន្តែ ជាការសំខាន់កាលណាសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលត្រូវធ្វើការទាក់ទងជាមួយអ្នកដទៃ។ ច្បាប់នេះត្រូវបញ្ជាក់ឲ្យច្បាស់ទាក់ទងនឹងការចេញវិញ្ញាបនប័ត្រចុះបញ្ជី។

| | | | |
|---|---|---|---|
| | | **៣. ការតវ៉ាតាមផ្លូវតុលាការ**<br>សេចក្ដីព្រាងច្បាប់នេះចែងថា សមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលដែលបម្រុងបង្កើតអាចប្ដឹងទៅតុលាការបាន បើក្រសួងសំរេចមិនចុះបញ្ជី។<br>វិធីនេះគ្មានលក្ខណៈអនុវត្តជាក់ស្ដែងសំរាប់អ្នកដាក់ពាក្យសុំចុះបញ្ជី។ គេត្រូវការពេលវេលា និងធនធានជាច្រើនដើម្បីអាចឲ្យអ្នកដាក់ពាក្យតស៊ូតាមផ្លូវតុលាការ ដើម្បីឲ្យតុលាការសំរេចពីការចុះបញ្ជី។ អាចស៊ីពេលរាប់ឆ្នាំ ដើម្បីទទួលបានសេចក្ដីសំរេចជាស្ថាពរ (នៅតុលាការកំពូលជាទូទៅ) នេះមិនទាន់គិតដល់ឯករាជ្យភាពនៃតុលាការទៀតផង។ ស្ថាបនិកនៃសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល នឹងចំណាយពេលលើថ្លៃសេវាច្បាប់យ៉ាងច្រើន មុននឹងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលកើតបានជានីតិបុគ្គលមួយ។ វាជាការគួរឲ្យអស់សំណើចណាស់ដែលគេត្រូវតស៊ូលើពាក្យសំដីរបស់លក្ខន្តិកៈ សូម្បីតែបដិវាទមែនទែនមិនទាន់កើតមានក៏ដោយ។<br>ដំណោះស្រាយតាមផ្លូវតុលាការមិនអាចមានសំរាប់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលតូចតាចទេ ព្រោះគេមានធនធានតិចតួចដើម្បីតស៊ូតាមផ្លូវតុលាការ។ នេះជាទម្រង់មួយនៃការរឹតត្បិតលើសិទ្ធិទទួលបានសេរីភាពក្នុងការបង្កើតសមាគម។ | |
| ៨ | ៩ | **មាត្រា ៩៖ មិនចុះបញ្ជី មិនអាចធ្វើសកម្មភាព**<br><br>មាត្រា ៩ បានពង្រីកការហាមប្រាមលើសកម្មភាពទាំងអស់ចំពោះអង្គការក្នុងស្រុក និងសមាគមណាដែលមិនចុះបញ្ជីដូចមានចែងក្នុងមាត្រា៤។ នេះជាមូលដ្ឋាននៃកម្រិតកំណត់នូវការការរិតត្បិតមិនសមមាត្រ ហើយអាចចាត់ទុកសកម្មភាពក្រុមសហគមមូលដ្ឋាន និងអង្គការសហគមដូចទៅនឹងអង្គការ ឬសមាគមក្នុងស្រុកដែរ។ រាល់សកម្មភាពគឺជាកម្ម វត្ថុដែលមានកំណត់នៅក្នុងទណ្ឌកម្មដែលមានចែងនៅក្នុងមាត្រា៣២ ហើយបើកឳកាសក្នុងកំណត់នូវបទល្មើសព្រហ្មទណ្ឌក្រោមក្រមព្រហ្មទណ្ឌ។ ពីមុនឡើយ អង្គការ និងសមាគមក្នុងស្រុកដែលមិនចុះបញ្ជីត្រូវបានបដិសេធដោយសមត្ថភាពផ្លូវច្បាប់ ប៉ុន្តែត្រូវបានអនុញ្ញាតឲ្យធ្វើសកម្មភាពបាន។<br>**ចំណោទ** | មាត្រា ៩ គួរត្រូវកែប្រែដូច្នេះថា ការទទួលស្គាល់ពីររដ្ឋាភិបាលមិនចាំបាច់ទេ។ ឧទាហរណ៍ មាត្រា៩គួរចែងថា "ច្បាប់នេះមិនកម្រិតនូវសិទ្ធិបុគ្គលចំពោះសេរីភាពនៃការបង្កើតសមាគមឡើយ"។<br>សេចក្ដីតម្រូវថា បើមិនចុះបញ្ជីមិនអាចធ្វើសកម្មភាពបាននោះ គឺជាការផ្ទុយនឹងប្រពៃណីខ្មែរ និងផ្ទុយនឹងនិយាមគតិយុត្តទូទៅនៃការទទួលស្គាល់សមាគម ឬក្រុមដែលមានទម្រង់ក្រៅផ្លូវការ។ |

| | | | |
|---|---|---|---|
| | | តើមានតែសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានទម្រង់ផ្លូវការប៉ុណ្ណោះដែលអាចធ្វើសកម្មភាពបាន?<br>**ក្រោមច្បាប់កម្ពុជា**<br>សេចក្តីព្រាងច្បាប់នេះទទួលស្គាល់តែសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានទម្រង់ផ្លូវការ ពីព្រោះច្បាប់នេះហាមឃាត់យ៉ាងល្វឹងល្វើយដល់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលណាដែលមិនបានចុះបញ្ជីមិនឲ្យធ្វើសកម្មភាព។ នៅប្រទេសកម្ពុជា មានសមាគមជាប្រពៃណីដែលជួយគ្នាទៅវិញទៅមក ដែលមានទម្រង់ក្រៅផ្លូវការ ប៉ុន្តែចូលទៅក្នុងនិយមន័យនៃសមាគម។ ឧទាហរណ៍ សមាគមជួយសំរាលទុក្ខបុណ្យសព សមាគមជួយស្ត្រីមេម៉ាយ សមាគមជួយគាំទ្រការធ្វើផ្លូវ។ សមាគមទាំងនេះអាចមានអត្ថិភាពរបៀបជាក្រៅផ្លូវការ ហើយជួនកាលមានអាយុស្មើនឹងត្រឹមតែរយៈពេលនៃគំរោង។ ចំពោះសមាគមទាំងនេះ ការចុះឈ្មោះមិនចាំបាច់ ឬ មិនអាចធ្វើបានតាមការអនុវត្តជាក់ស្តែង។ បើសេចក្តីព្រាងច្បាប់នេះអនុវត្តដោយតឹងរឹង ការបង្កើតសមាគមទាំងនេះនឹងត្រូវបង្អាក់ទឹកចិត្ត បើមិនដល់ថ្នាក់មិនអាចធ្វើបាន។<br>ក្រមរដ្ឋប្បវេណីមិនតម្រូវឲ្យបុគ្គលភាពណាមួយត្រូវចុះបញ្ជីឡើយ។ លក្ខខណ្ឌតែមួយគត់សំរាប់ការចុះបញ្ជី គឺដើម្បីបានភាពជានីតិបុគ្គល។ មាត្រា ៤៩ នៃក្រមរដ្ឋប្បវេណី ចែងថា៖ "នីតិបុគ្គលត្រូវបានបង្កើតឡើង ដោយការចុះបញ្ជីនៅកន្លែងដែលមានទីតាំងនៃស្នាក់ការកណ្តាលរបស់នីតិបុគ្គលនោះ"។ យោងតាមមាត្រា ៥០ នៃក្រមរដ្ឋប្បវេណី អត្ថប្រយោជន៍ដែលបានមកពីការចុះបញ្ជី គឺ ដើម្បីបានកិច្ចការពារតាមផ្លូវច្បាប់ដល់សមាជិកទល់នឹងភាគីទីបី ជាពិសេសទាក់ទងនឹងការទទួលខុសត្រូវចំពោះភាគីទីបី។ បើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលសុខចិត្តទទួលយកការទទួលខុសត្រូវនោះ នោះជាការទទួលយកហានិភ័យរបស់គេ ច្បាប់គ្មានប្រយោជន៍អ្វីត្រូវចាប់បង្ខំឲ្យគេចុះបញ្ជីទេ។ ប៉ុន្តែ ការរារាំងមិនឲ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលកើតបានដោយសារការមិនចុះបញ្ជី គឺជាការរំលោភសិទ្ធិទទួលបានសេរីភាពក្នុងការបង្កើតសមាគម។<br>សេចក្តីតម្រូវឲ្យចុះបញ្ជីនឹងមានផលប៉ះពាល់ដល់សេរីភាពក្នុងការបង្កើតសមាគមរបស់អង្គការសហគមន៍ ឧទាហរណ៍ សមាគមសហគមន៍នេសាទ សមាគមដើម្បីការពារធនធានធម្មជាតិ សមាគមជួយគ្នាទៅវិញទៅមក (ឧទាហរណ៍ សមាគមធនាគារស្រូវជាដើម)។ | |

| | | | |
|---|---|---|---|
| | | **ក្រោមច្បាប់អន្តរជាតិ**<br>ភាពដាច់ខាតនៃការចុះបញ្ជីគឺជាការរិត្បិតនូវការអនុញ្ញាតដែលមានចែងនៅក្នុងសេរីភាពនៃការបង្កើតសមាគមដែលមានចែងនៅក្នុងមាត្រា២២នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ។ មាត្រា២២ និងកតិកាសញ្ញាអន្តរជាតិផ្សេងៗទៀត "សេរីភាពនៃការបង្កើតសមាគមគឺជាសិទ្ធិមួយ ហើយមិនមែនជាអ្វីដែលត្រូវតែមានការអនុវត្តតំបូងដោយរដ្ឋាភិបាលទៅពលរដ្ឋខ្លួនឡើយ។[4] សមាគម និងអង្គការអាចត្រូវបានបង្កើត ជាអនីបុគ្គលមិនមែនមានន័យថា រូបវន្តបុគ្គលអាចតម្រូវឲ្យចុះបញ្ជីដើម្បីបង្កើតនីតិបុគ្គលដើម្បីបាននូវសេរីភាពនៃការបង្កើតសមាគមឡើយ។ ភាពដាច់ខាតនៃការចុះបញ្ជីគឺផ្នែកបញ្ហាដ៏សំខាន់ពេលដែលចុះបញ្ជីមានការលំបាកដើម្បីសម្រេចបាន ដូចដែលមានពិតនៅក្នុងសេចក្តីព្រាងច្បាប់នេះ ជាពិសេសគឺសម្រាប់អង្គការតូចៗដែលផ្តោតលើតម្រូវការកម្រិតសហគមនៃប្រយោជន៍សមាជិក។ ក្នុងកាលទេសនេះ រូបវន្តបុគ្គលត្រូវបានបង្ខំឲ្យជ្រើសរើសយកការធ្វើសកម្មភាពដូចក្រុមដែលមិនចុះបញ្ជីដូច្នេះភាពខុសច្បាប់ ឬស្វែងរកការចុះបញ្ជីដែលមានលក្ខខណ្ឌស្មុគ្រស្មាញ[5]។ | |
| ៩ | ១០ | **មាត្រា ១០៖ ពត៌មានអំពីគណនី**<br>**ចំណោទ**<br>តើអ្វីខ្លះជាពត៌មានគណនី?<br>តើជាឈ្មោះនិងលេខ គណនី ឬ ជាប្រតិបត្តិការគណនី?<br>បើវាជាប្រតិបត្តិការគណនី តើការសុំឲ្យបង្ហាញពីរបាយការណ៍នៃប្រតិបត្តិការគណនីជាការត្រូវតាមច្បាប់ដែរឬទេ?<br>**ការវិភាគ**<br>មាត្រា ១០ តម្រូវឲ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ផ្តល់ពត៌មានជាលាយលក្ខណ៍អក្សរអំពីរាល់គណនីធនាគារ ដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះមាន ក្នុងរយៈពេល ៣០ ថ្ងៃចាប់ពីថ្ងៃចុះបញ្ជី។ | |

[4] Public International Law Initiative, *Enabling Civil Society: Practical Aspect of Freedom of Association Source Book* (Budapest 2003), p.4

[5] នៅក្នុងមាត្រា ២១ ហាក់ដូចជារារាំងក្រុមដែលមិនចុះបញ្ជីមិនឲ្យធ្វើសកម្មភាពជាមួយដៃគូដើម្បីអនុវត្តគម្រោងជំនួយ

| | | | |
|---|---|---|---|
| | | ឈ្មោះនិងលេខគណនី ជាទូទៅត្រូវបានផ្តល់ដោយម្ចាស់គណនីទៅឲ្យភាគីទីបី ដែលគេជួញដូរ ឬមានកិច្ចការជាមួយគ្នា។ ប៉ុន្តែ ប្រតិបត្តិការគណនីគឺជាពត៌មានមិនអាចបើកបង្ហាញបាន។ មាត្រា ៣៧ នៃច្បាប់ស្តីពីគ្រឹះស្ថាន (១៩៩៩) ចែងថា មនុស្សម្នាក់នៅក្នុងគ្រឹះស្ថានមិនអាចបើកបង្ហាញពត៌មានសំងាត់នៅក្នុងសេចក្តីប្រកាស តួលេខ ឬអត្ថន័យនៃឯកសារគណនេយ្យទៅឲ្យភាគីទីបីបានទេ លើលែងតែទៅអាជ្ញាធរតុលាការក្នុងក្របខណ្ឌនៃនីតិវិធីព្រហ្មទណ្ឌ។<br>**សេចក្តីសន្និដ្ឋាន**<br>គេមិនអាចដឹងច្បាស់ថា តើមាត្រា ១០ ចង់ដាក់កំហិតឲ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបញ្ចេញពីឈ្មោះនិងលេខ គណនី ឬពត៌មានលំអិតអំពីប្រតិបត្តិការគណនី។ បើសិនជាក្នុងករណីខាងក្រោយនោះ នេះគឺជាការរំលោភលើពត៌មានធនាគារដែលមិនត្រូវបើកបង្ហាញ។<br>ក្នុងករណីដាក់ពាក្យសុំដូរឬកែប្រែលក្ខខន្តិកៈមិនគួរឲ្យបង់ប្រាក់ ឬបង់តិចតួចបានហើយ។ | |
| ១០ | ១១ | **មាត្រា ១១៖ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការចុះបញ្ជី**<br>**ចំណោទ**<br>១. តើមានលក្ខខណ្ឌណាផ្សេងទៀត (ក្រៅពីលក្ខណៈវិនិច្ឆ័យនៅក្នុងមាត្រា ៨) ដែលត្រូវដាក់លើ ការចុះបញ្ជីដែរឬទេ?<br>២. តើនីតិវិធីចុះបញ្ជីត្រូវកំណត់នៅក្នុងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ឬនៅ ក្នុងប្រកាសនៃក្រសួងមហាផ្ទៃ?<br>**ការវិភាគ**<br>មាត្រា ១១ នៃសេចក្តីព្រាងច្បាប់ចែងថា ក្រសួងមហាផ្ទៃត្រូវចែងពីលក្ខខណ្ឌ បែបបទ និង នីតិវិធីនៃការចុះបញ្ជីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស។<br>នៅពេលនេះ គេមិនអាចដឹងច្បាស់ថា តើមានលក្ខខណ្ឌប៉ុន្មានទៀតដែលលាក់បំបាំង ដែលនឹងត្រូវដាក់ចូលក្នុងប្រកាស ឬ គ្រាន់តែឲ្យប្រកាសនោះបំភ្លឺលំអិតថែមទៀតទៅលើពាក្យទាំងឡាយដែលគ្មាននិយមន័យច្បាស់លាស់ដូចជាពាក្យ "សន្តិសុខជាតិ" "សណ្តាប់ធ្នាប់សាធារណៈ" ឬ ពាក្យផ្សេងទៀត។ នៅក្នុងមាត្រា ៨ ឯកសារដែលតម្រូវនៅក្នុងការចុះបញ្ជីមិនស្មុគស្មាញទេ ប៉ុន្តែ បើមានបែបបទផ្សេងទៀតដែលប្រកាសទាមទារឲ្យដាក់ដើម្បីចុះបញ្ជី នោះវានឹងបង្កើតការលំបាក ឬ សោហ៊ុយដើម្បីចុះបញ្ជី។ ដូចគ្នា | ដើម្បីឲ្យសេចក្តីព្រាងច្បាប់នេះដោះស្រាយតែម្តងឲ្យចប់សព្វគ្រប់ សេចក្តីព្រាងច្បាប់នេះត្រូវចែងពីនីតិវិធីនេះឲ្យរួចរាល់តែម្តងទៅ។ |

| | | | |
|---|---|---|---|
| | | ដែរ វាអាចមានលក្ខខណ្ឌថែមទៀតដែលដាក់លើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ហើយលក្ខខណ្ឌទាំងនោះអាចផ្ទុយនឹងសេចក្តីព្រាងច្បាប់នេះ នេះម្យ៉ាង ហើយនិងម្យ៉ាងទៀត អាចផ្ទុយនឹងនិយាមគតិយុត្តដែលមានស្រាប់ ដូចជារដ្ឋធម្មនុញ្ញ និងឧបករណ៍អន្តរជាតិដទៃទៀត។ | |
| ១១ | ១២ | **មាត្រា ១២៖ ការចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស**<br>**ចំណោទ**<br>តើអ្វីជាគំរោងរយៈពេលខ្លី?<br>**ការវិភាគ**<br>សេចក្តីព្រាងច្បាប់គួរបញ្ជាក់បំភ្លឺរវាង ការិយាល័យប្រចាំប្រទេស និង ការិយាល័យគំរោង។ អង្គការបរទេសខ្លះបានទទួលគំរោង ដែលមានរយៈពេលមួយ ដូចជា ៥ ឆ្នាំជាដើម។ កាលណាគំរោងចប់ ការិយាល័យនៃអង្គការនោះត្រូវបិទ។ តើគំរោងរយៈពេលខ្លីត្រូវវាស់វែងជាចំនួនឆ្នាំ ឬ វាស់វែងតាមគំរោងនីមួយៗ? ឧទាហរណ៍ បើគំរោងមានរយៈពេលតិចជាង ៣ ឆ្នាំ គំរោងនោះត្រូវចាត់ទុកជាគំរោងខ្លី ឬមួយគំរោងត្រូវហៅថាគំរោងខ្លី? | បើអាចបែងចែករវាងការិយាល័យប្រចាំប្រទេស និងការិយាល័យគំរោង នោះជាការប្រសើរសំរាប់អង្គការបរទេស។ ហើយសេចក្តីព្រាងច្បាប់នេះគួរបែងចែកឲ្យច្បាស់រវាងអនុស្សារណៈនៃការយោគយល់គ្នា និងលិខិតអនុញ្ញាត។ |
| ១២ | ១៣ | **មាត្រា ១៣៖ ឯកសារសំរាប់ចុះឈ្មោះអង្គការបរទេស**<br>**ចំណោទ**<br>មាត្រានេះមានការមិនច្បាស់។ ការគាំទ្រពីក្រសួង ឬស្ថាប័នសាមី<br>**ការវិភាគ**<br>ចំណុច ១៣.៣ មានលក្ខណៈមិនច្បាស់ ថាតើពាក្យសុំចុះឈ្មោះនោះទាមទារឲ្យមានវិញ្ញាបនប័ត្រចុះបញ្ជីដែលចេញឲ្យដោយប្រទេសដើម ឬ ជាការបញ្ជាក់ដោយប្រទេសដើមថា អង្គការដែលសុំចុះបញ្ជីនៅប្រទេសខ្មែរអាចធ្វើសកម្មភាពនៅប្រទេសក្រៅបាន។<br>ចំណុច ១៣.៤ ទាមទារឲ្យមានការគាំទ្រពីក្រសួង ឬស្ថាប័នសាមី ដើម្បីឲ្យអង្គការឬសមាគមបរទេសមួយអាចបើកការិយាល័យប្រចាំប្រទេស ឬ ការិយាល័យគំរោង។ បើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសមិនអាចសុំការគាំទ្របានពីក្រសួង ឬស្ថាប័នសាមី នោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសនោះមិនអាចធ្វើសកម្មភាពនៅប្រទេសកម្ពុជាបានទេ។ | |

| | | | |
|---|---|---|---|
| | | ដោយហេតុថា អនុស្សារណៈនៃការយោគយល់គ្នាបង្កើតជាទំនាក់ទំនងកិច្ចសន្យារវាងក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស គេមិនអាចដឹងពី ខ និង លក្ខខណ្ឌនៃកិច្ចសន្យានោះ។ ដូច្នេះ គេក៏មិនអាចដឹងថាតើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស អាចមានចន្លោះសមរម្យសំរាប់ប្រតិបត្តិការរបស់ខ្លួន ឬមានចន្លោះចង្អៀតចង្អល់ដើម្បីធ្វើការរបស់ខ្លួន។ | |
| ១៣ | ១៤ | **មាត្រា ១៤**<br>ក្រសួងពិនិត្យមើលពាក្យសុំក្នុងអំឡុងពេល៤៥ថ្ងៃនៃថ្ងៃធ្វើការក្នុងការសម្រេចថាត្រូវ ឬមិនត្រូវចុះអនុស្សារណៈ | |
| ១៤ | ១៥ | **មាត្រា ១៥**<br>សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក "ត្រូវពិភាក្សា និងយល់ព្រមជាមួយនឹងអាជ្ញាធរសាធារណៈលើគម្រោងឬកម្មវិធីមុនពេលដាក់ពាក្យសុំចុះអនុសារណៈយោគយល់ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ....″ លិខិតដែលចេញដលយអាជ្ញាធរសាធារណៈក្នុងការគាំទ្រលើគម្រោងរបស់អង្គការបរទេសត្រូវមានសរសរបញ្ចូលនៅក្នុងផ្នែកនៃដំណើការនៃការចុះបញ្ជីដូចមានកំណត់នៅក្នុងមាត្រា ១៣។ | |
| ១៥ | ១៦ | **មាត្រា ១៦**<br>មាត្រា ១៦នេះ កំណត់អំពីសុពលភាពនៃអនុស្សារៈមិនឲ្យលើសពី៣ឆ្នាំឡើយ ហើយតម្រូវឲ្យអង្គការបរទេសទាំងនោះដែលមានបំណងបន្តសកម្មភាពនៅក្នុងប្រទេសកម្ពុជាត្រូវដាក់សំណើរសុំបន្តអនុស្សារៈនោះទៀត។ ដូច្នេះជាសំខាន់គឺ អង្គការអន្តរជាតិជាកម្មវត្ថុនៃដំណើរការនៃការចុះបញ្ជីជាថ្មីម្តងទៀត។ តំណាងពិសេសអង្គការសហប្រជាជាតិស្តីពីស្ថានភាពអ្នកការពារសិទ្ធិមនុស្សមានក្តីបារម្ភនៅលក្ខខណ្ឌនៃការចុះបញ្ជីជាថ្មីនេះ៖ "នៅក្នុងប្រទេសមួយចំនួនតម្រូវឲ្យចុះឈ្មោះម្តងទៀតនៅក្នុងពេលជាក់លាក់ណាមួយជាមួយនឹងពេលលេវាលច្បាស់លាស់អាជារាងរាល់ឆ្នាំ ឬជាញឹកញាប់ដែលផ្តល់ឪកាសដល់ រដ្ឋាភិបាលក្នុងហាមប្រាមនូវសកម្មភាពរបស់ក្រុមដែលធ្វើសកម្មភាពមិនទទួលការយល់ព្រមពី រដ្ឋាភិបាល។ | |

| | | | |
|---|---|---|---|
| | | លក្ខខណ្ឌនៃអំឡុងពេលសម្រាប់ការចុះបញ្ជីជាថ្មីអាចជាលក្ខខណ្ឌនូវកម្រិតមួយនៃអសន្តិសុខ....ដែលចេញមកពីការកៀបសង្កត់ខ្លួនឯង និងការគម្រាមកំហែង"[6] | |
| ១៦ | ១៧ | **មាត្រា ១៧៖ ផ្តល់ព័ត៌មានអំពីគណនីដោយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស**<br>សមាគម ឬអង្គការបរទេសនៅក្នុងប្រទេសកម្ពុជាត្រូវជូនដំណឹងទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនូវគណនេយ្យធនាគាររបស់ខ្លួនក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេល៣០ថ្ងៃបន្ទាប់ពីចុះហត្ថលេខាលើអនុស្សារៈ។ | |
| ១៧ | ២៤ | **មាត្រា ២៤ អព្យាក្រិត្យភាពនិងការដាក់ទោសសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល**<br>**ចំណោទ**<br>តើ "អព្យាក្រិត្យភាព" ជាការជ្រើសរើស ឬ ជាកម្មវត្ថុនៃការកំណត់ដោយច្បាប់?<br>**ការវិភាគ**<br>មាត្រា ២៤ ចែងថា សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលត្រូវប្រកាន់ជំហរអព្យាក្រិត្យចំពោះគណបក្សនយោបាយទាំងអស់នៅកម្ពុជា។ ក្រសួងមហាផ្ទៃអាចព្រមានសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលអំពីការលំអៀង ហើយបើការលំអៀងនេះនៅតែមាន ក្រសួងអាចលុបឈ្មោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលចេញពីបញ្ជី។<br>ក្នុងអតីតកាលកន្លងមក រដ្ឋាភិបាលបានត្អូញត្អែថាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលខ្លះមានការលំអៀងទៅរកគណបក្សប្រឆាំង។ នេះមកពីសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលនោះចេញសេចក្តីថ្លែងការណ៍ ឬបញ្ចេញរបាយការណ៍ដែលរិះគន់រដ្ឋាភិបាលនៅក្នុងបញ្ហាអភិបាលកិច្ច ជម្លោះដីធ្លី អំពើពុករលួយ ការគ្រប់គ្រងធនធានធម្មជាតិ ការរំលោភសិទ្ធិមនុស្សជាដើម។ បញ្ហាទាំងនេះ ខ្លះគាប់ជួនជាមួយនឹងបញ្ហាដែលធ្វើយុទ្ធនាការដោយគណបក្សប្រឆាំង ឬ ត្រូវបានស្រង់យកដោយគណបក្សប្រឆាំងទៅដាក់ក្នុងរបៀបវារៈនៃយុទ្ធនាការ ឬគោលនយោបាយរបស់គេ។ | ហេតុដូច្នេះ អានុភាពនៃការបង្គាប់ឲ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលប្រកាន់អព្យាកត្យភាពគឺនាំឲ្យមានការកាត់បន្ថយ (បើមិនដល់បំបាត់) សិទ្ធិទទួលបានសេរីភាពនៃមតិ។ ជាចុងក្រោយ គ្មានមូលដ្ឋានច្បាប់ជាតិ ឬ អន្តរជាតិណាមួយ ដែលបើឲ្យរដ្ឋាភិបាលធ្វើបញ្ញត្តិអំពីអព្យាក្រិត្យភាព ទៅលើអង្គការពលរដ្ឋបានទេ។ អព្យាក្រិត្យភាពនេះជាការជ្រើសរើសរបស់អង្គការសាមី គឺមិនមែនជាកាតព្វកិច្ចទេ។ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលអាចប្រព្រឹត្តខ្លួនឯងដោយអព្យាក្រិត្យ ក្នុងគោលបំណងរក្សាទំនាក់ទំនងសាធារណៈ ឬ អាចជ្រើសរើសយកការប្រកាន់ជំហររឹងមាំ |

[6] របាយការដែលបានដាក់ដោយបេសកជនពិសេសតំណាងអង្គការសហប្រជាជាតិ Magraret Sukaggya, ស្តីពីស្ថានភាពអ្នកការសិទ្ធិមនុស្សនៅក្នុងដំណោះស្រាយសន្និបាតអង្គការសហប្រជាជាតិ 62/152 (4 August 2009) p.28 (http://www.icj.org/IMG/report_of_sr_on_hrds_to_ga.pdf)

| | | | |
|---|---|---|---|
| | | សេចក្តីថ្លែងងការណ៍ ឬ របាយការណ៍បញ្ចេញនូវទិន្នន័យ ឬមតិ ដែលរិះគន់ដល់រដ្ឋាភិបាល និងគណបក្សកាន់អំណាច។ ដោយមកពីទិន្នន័យ ឬមតិ មិនអំណោយផលដល់ខ្លួនទាំងនោះ ទើបរដ្ឋាភិបាល/គណបក្សកាន់អំណាចចោទប្រកាន់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលថាគាំទ្រគណបក្សប្រឆាំង ហើយដូច្នេះ បង្ហាញនូវជំហរមិនអព្យាក្រិត្យចំពោះគណបក្សនយោបាយ។<br>ជំហរអាចបញ្ចេញមកក្រៅតាមរយៈមតិ ឬការសំដែង។ បញ្ច្រាស់មកវិញ ដើម្បីសំដែងថាខ្លួនមិនប្រកាន់ជំហរ មនុស្សម្នាក់ត្រូវចៀសវាងមិនបញ្ចេញមតិ ឬការសំដែងណាមួយ។ ដាក់បញ្ញត្តិលើជំហរ មានន័យថាដាក់បញ្ញត្តិលើមតិ។<br>**យោងតាមក្របខណ្ឌគតិយុត្តជាតិ**<br>រដ្ឋធម្មនុញ្ញកម្ពុជា ប្រទានសេរីភាពនៃមតិដល់ប្រជាពលរដ្ឋខ្មែរ (មាត្រា ៤១)។ រដ្ឋធម្មនុញ្ញមិនបានរឹតត្បិតលើមតិនយោបាយ ឬ មតិដែលលំអៀងទៅរកឯកត្តបុគ្គល ឬ បុគ្គលភាណណាមួយឡើយ។ ការរឹតត្បិតតែម្យ៉ាងគឺការសំដែងអង្គហេតុណាមួយដែលប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់អ្នកដទៃ ប្រពៃណីល្អរបស់សង្គម សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម។<br>លើសពីនេះទៀតរដ្ឋធម្មនុញ្ញលើកទឹកចិត្តឲ្យពលរដ្ឋចូលរួមយ៉ាងសកម្មនៅក្នុងសកម្មភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ប្រជាជាតិ (មាត្រា ៣៥)។ ការចូលរួមសកម្មភាពទាមទារឲ្យមានវិភាគទានយ៉ាងហ៊ឹកហ៊ាក់ ឬ ស្វាហាប់ដល់សកម្មភាពទាំងនោះ រួមទាំងការចែករំលែកពត៌មាន, គំនិត, និង មតិ។ ការខ្ទប់ច្របាច់សេរីភាពនេះ គឺជាការលុបបំបាត់មតិតែម្តង និងកាត់សេរីភាពក្នុងការចូលរួម។<br>**យោងតាមក្របខណ្ឌគតិយុត្តអន្តរជាតិ**<br>កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ មាត្រា ១៩ ផ្តល់ឲ្យនូវសេរីភាពនៃមតិៈ<br>១.មនុស្សរាល់រូបមានសិទ្ធិដើម្បីប្រកាន់មតិដោយគ្មានការជ្រៀតជ្រែក។<br>២.មនុស្សរាល់រូបមានសិទ្ធិទទួលបានសេរីភាពក្នុងការសំដែងចេញ។ សិទ្ធិនេះរួមមានសេរីភាពដើម្បីស្វែងរក ទទួល និង បញ្ចេញពត៌មាន និងគំនិត គ្រប់យ៉ាងទាំងអស់ ដោយមិនគិតពីព្រំដែន ជាផ្ទាល់មាត់ក្តី ជាសំណេរក្តី ឬ ជាការបោះពុម្ពក្តី ក្នុងទម្រង់ជាសិល្បៈក្តី ឬតាមរយៈប្រព័ន្ធផ្សាយពត៌មានតាមការជ្រើសរើសរបស់គេក្តី។<br>[[...] | ណាមួយក្នុងគោលបំណងតស៊ូមតិរបស់គេ។<br>អព្យាក្រិត្យភាពនេះ អាចបញ្ញត្តិតាមក្រមសីលធម៌ មិនមែនតាមច្បាប់ទេ។ |

| | | | |
|---|---|---|---|
| | | ដូចគ្នានឹងរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាដែរ ច្បាប់អន្តរជាតិលើកស្ទួយមតិដែលគ្មានការត្រួតពិនិត្យ និងលំហូរដោយសេរីនូវព័ត៌មាន និងគំនិតរវាងអ្នកដែលចែកចាយ និងអ្នកដែលទទួល មតិ ព័ត៌មាន និង គំនិតទាំងនោះ។ មតិ ព័ត៌មាន និង គំនិតអាចមិនអំណោយផលដល់ភាគីមួយ ឬ មិនអំណោយផលដល់ភាគីទាំងពីរដែលផ្ទុយគ្នា។ ភាគីដែលទទួលមតិមានអំណោយផលដល់ខ្លួននឹងវិនិច្ឆ័យថា អ្នកបញ្ចេញមតិជាអ្នកអព្យាក្រិត្យ រីឯអ្នកដែលទទួលមតិមិនមានអំណោយផលដល់ខ្លួននឹងចាត់ទុកអ្នកបញ្ចេញមតិជាអ្នកអគតិមករកខ្លួន។ គ្មានស្តង់ដាណាមួយដើម្បីវាស់វែងពីអព្យាក្រិត្យភាពទេ ពីព្រោះ ការវាស់វែងនោះកើតចេញពីគំនិតអត្តនោម័ត។ មនុស្សម្នាក់ដែលវិនិច្ឆ័យថាមនុស្សម្នាក់ទៀតថាមិនអព្យាក្រិត្យចំពោះភាគី ក អាចធ្លាក់ទៅក្នុងការវិនិច្ឆ័យរបស់ ក ថាជាអ្នកលំអៀងទៅរកភាគី ខ។<br>គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ នៅក្នុងសេចក្តីអធិប្បាយលេខ ៣៤ របស់ខ្លួន បញ្ជាក់សង្កត់ថា "គ្រប់ទម្រង់នៃមតិត្រូវបានការពារ រួមទាំងមតិដែលមានលក្ខណៈជានយោបាយ វិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សីលធម៌ ឬ សាសនា" (កថាខណ្ឌ ៩) ហើយថា "ការ**លាបពណ៌**មនុស្សណាម្នាក់ ... ដោយសារហេតុផលនៃមតិដែលគេប្រកាន់យក គឺជាការរំលោភលើមាត្រា ១៩ កថាខណ្ឌ ១" (កថាខណ្ឌ ៩)។ គណៈកម្មាធិការបន្តទៀតថា "ពេលណារដ្ឋជាភាគីធ្វើការរឹតត្បិតលើការអនុវត្តសេរីភាពនៃការសំដែងចេញ ការរឹតត្បិតនោះមិនអាចធ្វើឲ្យអន្តរាយដល់សិទ្ធិនោះតែម្តងទេ" (កថាខណ្ឌ ២១)។ ក្នុងករណីនៃច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ការត្រួតត្រាលើជំហរគឺជាការបំបាត់មតិ ឬ ការសំដែងចេញ ពីព្រោះការត្រួតត្រានោះនឹងធ្វើឲ្យមនុស្សឈប់បញ្ចេញមតិនិងការសំដែងចេញរបស់ខ្លួន ហើយនឹងបញ្ឈប់ឲ្យមនុស្សនោះឈប់ចែកចាយព័ត៌មាន និងគំនិត ឬ នឹងធ្វើឲ្យមនុស្សនោះចែកចាយព័ត៌មានដែលមានការត្រួតពិនិត្យ ដើម្បីចៀសវាងកុំឲ្យគេលាបពណ៌ថាលំអៀង។<br>ការបង្ខំដាក់លក្ខខណ្ឌគ្មានមូលដ្ឋានដល់សមាគម និងអង្គការឲ្យមានភាព "អាព្យាក្រិត្យគ្រប់គណបក្សនយោបាយទាំងអស់" មិនត្រូវទៅនឹងចំណុចសាកល្បងចំនួនបី។ ទី១ លក្ខខណ្ឌគឺមិនច្បាស់លាស់ដែលខុសពីគោលការណ៍នៃភាពអាចទុស្សទាយបាន ឬតម្លាភាព។ ទី២ ការរិតត្បិតមិនត្រូវទៅនឹងគោលដៅដែលមានចែងនៅក្នុងមាត្រា ១៩(៣)នៃកតិកាសញ្ញានៃសិទ្ធិពលរដ្ឋ និងនយោបាយ។ ទី៣ គ្មានការចង្អុលបង្ហាញដែលថា ការរិតត្បិតនេះជាការចាំបាច់ ឬយ៉ាងហោចណាស់មធ្យោបាយនៃការរិតត្បិតនេះត្រូវទៅនឹងគោលបំណង។ វាស្មើរតែគ្រប់អង្គការ ឬសមាគម វាជាផ្នែកមួយនៃការអនុវត្ត បេសកម្មរបស់គេ | |

| | | | |
|---|---|---|---|
| | | អាចស្វែងរកគោលជំហ៊រមួយស្តីពីបញ្ហាសំខាន់ជាសធារណៈ ក្នុងសម្មភាពចឹងៗ ទោះជាយ៉ាងណាក្តី សមាគម ឬអង្គការអាចជួបនឹងបញ្ហានៃការបកស្រាយថាមានភាពលំអៀង។ដូច្នេះ លក្ខខណ្ឌនេះគឺជាការរិតត្បិតដែលមិន អនុញ្ញាតនៅក្នុងសេរីភាពនៃការបញ្ចេញមតិ វាលែងតែមានកំណត់នៅក្នុងវិធាន វានឹងអាចនាំឲ្យមានការកៀបសង្កត់ដែលធ្វើឲ្យមិនពេញចិត្ត និងរងការរិះគន់ និងអាចប្រើប្រាស់នូវការរាំងដោយឯកឯងក្នុងការចុះបញ្ជីសមាគមន និងអង្គការ ឬអាចត្រូវបានប្រើជាមូលដ្ឋានសម្រាប់ការបញ្ចប់សុពលភាពនៃការចុះបញ្ជី។<br>**ការដណ្តើមយកអំណាចតុលាការ**<br>សេចក្តីព្រាងច្បាប់អនុញ្ញាតឲ្យក្រសួងមហាផ្ទៃជាអ្នកវិនិច្ឆ័យអំពីអព្យាក្រិត្យភាពនៃសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល និងដាក់ទណ្ឌកម្មផ្អាក ឬ លុបចោលពីបញ្ជី (មាត្រា ៣០)។<br>យោងតាមក្រមរដ្ឋប្បវេណី មានមូលហេតុ ៦ យ៉ាងសំរាប់ការលុបនីតិបុគ្គលចេញពីបញ្ជី ហើយគ្មានមូលហេតុណាមួយត្រូវបានសំរេចដោយអាជ្ញាធររដ្ឋបាលទេ (មាត្រា ៦៤)។ យោងតាមមាត្រានេះ នីតិបុគ្គលអាចត្រូវបានរំលាយដោយខ្លួនឯង ដោយសមាជិក ក្ស័យធន ឬ **ដោយតុលាការ**។ ហើយជាថ្មីម្តងទៀត ដូចបានពិពណ៌នាពីមុនមក ការដកហូតសិទ្ធិពលរដ្ឋនៅក្រោមប្រព័ន្ធច្បាប់ព្រហ្មទណ្ឌ អាចធ្វើបានតាមរយៈសាលក្រមតុលាការ។<br>ការអនុញ្ញាតឲ្យក្រសួងមហាផ្ទៃធ្វើសេចក្តីវិនិច្ឆ័យដកហូតសិទ្ធិគ្រឹះក្នុងការបង្កើតសមាគមនៃសមាគម ឬអង្គការក្រៅរដ្ឋាភិបាល គឺជាការរំលោភលើគោលការណ៍ធម្មនុញ្ញនៃការបែងចែកអំណាច និងការរំលោភលើក្របខណ្ឌគតិយុត្តដែលមានស្រាប់។ មាត្រា ១២៨ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា តុលាការមានអំណាចឯករាជ្យ ការពារសិទ្ធិ និងសេរីភាពរបស់ពលរដ្ឋ មានសមត្ថកិច្ចលើរឿងក្តីទាំងអស់ រួមទាំងក្តីរដ្ឋបាល។ នៅក្នុងការអនុវត្តអំណាចតុលាការ តុលាការកំពូល និងតុលាការគ្រប់ជាន់ថ្នាក់ ជាអ្នកមានអំណាចសំរេចសេចក្តី។ ដូច្នេះ ក្រសួងមហាផ្ទៃគ្មានអំណាចស្របតាមរដ្ឋធម្មនុញ្ញដើម្បីបំពេញនាទីជាតុលាការបានទេ រួមទាំងតុលាការរដ្ឋបាលផងដែរ ដើម្បីដកហូតយកសិទ្ធិធម្មនុញ្ញរបស់ពលរដ្ឋ។ | |
| ១៨ | ២៥ | **មាត្រា ២៥ ៖ ការផ្តល់របាយការណ៍សកម្មភាពនិងហិរញ្ញវត្ថុ និងទណ្ឌកម្មមកពីការមិនដាក់ របាយការណ៍ ទាំងនេះ**<br>**ចំណោទ** | **សេចក្តីសន្និដ្ឋាន**<br>របាយការណ៍អាចដាក់ជូននៅក្នុងទម្រង់ណាដែលសំរួលដល់សមាគម |

| | | | |
|---|---|---|---|
| | | តើក្រសួងមហាផ្ទៃអាចផ្អាក ឬ រំលាយនីតិបុគ្គល ដោយសារមិនដាក់ជូនរបាយការណ៍សកម្មភាព និងហិរញ្ញវត្ថុប្រចាំឆ្នាំបានដែរឬទេ?<br>**ការវិភាគ**<br>មាត្រា ២៥ ចែករបាយការណ៍ជាពីរប្រភេទ៖ របាយការណ៍សកម្មភាព និងហិរញ្ញវត្ថុរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមិនទទួលជំនួយពីម្ចាស់ជំនួយ និង របាយការណ៍សកម្មភាព និងហិរញ្ញវត្ថុនៃសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលទទួលជំនួយពីម្ចាស់ជំនួយ។<br>ចំពោះប្រភេទទីមួយ ក្រសួងទាមទារតែរបាយការណ៍សរុបសកម្មភាព និងហិរញ្ញវត្ថុ។ ចំពោះប្រភេទទីពីរ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលត្រូវផ្តល់ជូននូវឯកសារគម្រោង កិច្ចព្រមព្រៀងផ្តល់ជំនួយ និងសំណៅចម្លងចេញពីរបាយការណ៍ប្រចាំឆ្នាំខាងសកម្មភាព និងហិរញ្ញវត្ថុទៅម្ចាស់ជំនួយ។<br>សេចក្តីតម្រូវឲ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលចម្លងរបាយការណ៍សកម្មភាព និងហិរញ្ញវត្ថុប្រចាំឆ្នាំនេះ ប្រហែលជាការឆ្លើយតបរបស់រដ្ឋាភិបាលចំពោះការរិះគន់របស់ក្រុមសង្គមស៊ីវិលនៅឆ្នាំ ២០១១ ដែលថាការតម្រូវឲ្យរាយការណ៍នេះ ជាការធ្ងន់ធ្ងរសម្រាប់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ព្រោះគេត្រូវរៀបចំរបាយការណ៍ឲ្យម្ចាស់ជំនួយជាច្រើនក្នុងពេលតែមួយ។<br>របាយការណ៍ដែលត្រូវដាក់ជូនរដ្ឋាភិបាលនឹងក្លាយទៅជាឯកសារសាធារណៈ។ ដូច្នេះ ការសម្ងាត់នៃប្រភពផ្តល់ពត៌មាន នឹងមិនត្រូវបានការពារ ឬ នឹងនាំឲ្យប្រភពពត៌មានស្ថិតក្នុងគ្រោះថ្នាក់កាលណារបាយការណ៍អាចសាធារណជនមើលបាន។<br>ការដាក់ទណ្ឌកម្មមានលក្ខណៈវិសមាមាត្រ។ ការមិនបានដាក់របាយការណ៍គឺជាបញ្ហាផ្នែករដ្ឋបាល ដែលមិនត្រូវមានទណ្ឌកម្មត្រូវដកហូតសិទ្ធិពលរដ្ឋ។<br>មាត្រា២៥ ក៏អនុញ្ញាតឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអាជ្ញាធរសវនកម្មជាតិធ្វើការត្រួតពិនិត្យ និងសវនកម្មលើអង្គការ និងសមាគមក្នុងស្រុក និងបរទេស"ក្នុងករណីចាំបាច់" ហើយក្រសួងមហាផ្ទៃអាចទាមទារឲ្យផ្ញើរនូវរបាយការណ៍សកម្មភាពការងារ និងហិរញ្ញវត្ថុបន្ថែមទៀតពីអង្គការ និងសមាគមក្នុងស្រុក "ក្នុងករណីចាំបាច់"។ ពាក្យ "ក្នុងករណីចាំបាច់" គឺមានភាពស្រពិចស្រពិល ហើយអាចជាកម្មវត្ថុនៃការប្រើវាតាមចិត្តលើសមាគម និងអង្គការដើម្បីជ្រៀតជ្រែកដោយខុសច្បាប់លើសកម្មភាព និងរបាយការណ៍សម្ងាត់ផ្សេងទៀតរបស់អង្គភាពនោះ។ នេះជាការបារម្ភមួយពីព្រោះគ្មានការផ្តល់និយមន័យអំពី | ឬអង្គការមិនមែនរដ្ឋាភិបាល ក្នុងផលប្រយោជន៍ការពារការសម្ងាត់របស់ប្រភពពត៌មាន។<br>គ្មានការចាំបាច់ដែលត្រូវដាក់សេចក្តីតម្រូវខាងសវនកម្មនេះនៅក្នុងសេចក្តីព្រាងនេះទេ។ |

| | | | |
|---|---|---|---|
| | | លក្ខខណ្ឌ ឬបទដ្ឋានលើទំហំនៃសវនកម្ម ឬការទាមទារនូវឯកសារបន្ថែមទៀត។ សមាគមន និងអង្គការគ្មានសិទ្ធិក្នុងការតវ៉ាចំពោះសេចក្តីសម្រេចទាំងនេះឡើយ។<br>សេចក្តីព្រាងច្បាប់នេះបានកំណត់នូវបន្ទុកលក្ខខណ្ឌរបាយការណ៍មួយយ៉ាងសាំញ៉ាំសម្រាប់សមាគមក្នុងស្រុក និងបរទេស។ សេចក្តីព្រាងច្បាប់នេះតម្រូវឲ្យគ្រប់សមាគម និងអង្គការត្រូវដាក់ថតចម្លងគ្រប់របាយការណ៍ដែលផ្ញើទៅម្ចាសមូលនិធិ។ បន្ថែមពីលើនេះទៀត វាមានលក្ខខណ្ឌជាមុនដេលថា គ្រប់សំណើរមូលនិធិ និងហិរញ្ញវត្ថុ ឬអំណោយដែលទទួលបានត្រូវតែដាក់ទៅក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច។ សមាគម និងអង្គការជាញឹកញាប់មានលក្ខខណ្ឌរបាយការណ៍ទៅម្ចាស់ មូលនិធិទាំងអស់។ តម្រូវការឲ្យពួកគេដាក់នូវរាល់របាយការណ៍សំខាន់នីមួយៗដែលបានផ្ញើរទៅម្ចាស់មូលនិធិនីមួយៗគឺជា រឿងមួយមិនសម្បាយចិត្ត និងទំនងជាជះឥទ្ធិពលលើសមត្ថភាពនៃការអនុវត្តគម្រោង ដោយបង្កើននូវចំណាយលើថ្លៃរដ្ឋបាល និងជះឥទ្ធិពលដល់ទំនាក់ទំនងជាមួយម្ចាស់មូលនិធិផងដែរ។<br>បន្ថែមពីនេះទៀត គ្រប់សមាគម និងអង្គការ "ទទួលការគាំពារហិរញ្ញវត្ថុ" និងគ្រប់អង្គការបរទេសត្រូវតែថតចម្លងរបាយការណ៍ប្រចាំឆ្នាំដែលដាក់ទៅម្ចាស់មូលនិធិទៅអាជ្ញាធររដ្ឋាភិបាល។ របាយការណ៍ដាក់ទៅម្ចាស់មូលនិធិអាចរួមមានព័ត៌មានសម្ងាត់ដែលមិនទាក់ទងនឹងសកម្មភាពការងារសមាគមផ្ទាល់ និងដូច្នេះលក្ខខណ្ឌនេះទំនងជារំលោភលើសិទ្ធិរក្សាការសម្ងា[7]។ ជាមូលដ្ឋាន ចំណុចទាំងនេះជាការជ្រៀតជ្រែងរបស់រដ្ឋាភិបាលនៅក្នុងកិច្ចសន្យាឯកជន។ វាមិនទំនងសម្រាប់រដ្ឋភិបាលដែលតម្រូវឲ្យអ្នករកប្រាក់ចំណេញត្រូវតែធ្វើរបាយការណ៍អំពីការព្រមព្រៀងរវាងភាគីឯកជនទាំងពីរឡើយ។ ក្នុងករណីដែលសមាគម និងអង្គការ ថាតើរដ្ឋាភិបាលបានទទួលរបាយការណ៍ប្រចាំឆ្នាំលើសកម្មភាពការងារ និងហិរវត្ថុរួចហើយនោះ ថាត្រូវយករបាយការណ៍បន្ថែមតាមការចាំបាច់នោះមិនមានភាពច្បាស់លាស់នៅឡើយ។<br>ជាជម្រើស មួយអាចជាការស្រមៃនៅប្រព័ន្ធមួយដែលអង្គភាពគ្មានផលប្រយោជន៍ ឬមូលនិធិសាធារណៈអាចត្រូវទទួលខុសត្រូវចំពោះសមាជិករបស់ពួកគេ ប៉ុន្តែគ្មានតម្រូវឲ្យមានរបាយការណ៍ទេ។ អង្គការទាំងនោះគួរតែមានភាពច្បាស់លាស់ក្នុងលក្ខខណ្ឌនៃរបាយការណ៍ ទោះបីជាទទួលផលប្រយោជន៍ពី | |

[7] Article 17 of the ICCP ready follows : "1. No one shall be subjected to arbitrary or unlawful interference with his privacy, family, home or correspondence, nor to unlawful attacks on his honor and reputation. 2. Everyone has the rights to the protection of the law against such interference or attacks." *See also,* Report of the Special Rapporteur on the rights of freedom of peaceful and of association, Maina Kiai, para.65, U.N.Doc.

| | | | |
|---|---|---|---|
| | | ពន្ធ ឬមូលនិធិសាធារណៈក៏ដោយ។ ភាពលំអិត និងភាពបែងចែកដាច់ពីគ្នាគួរតែធ្វើឲ្យបានច្បាស់លាស់បន្ទាប់ពីការពិភាក្សាប្រកបដោយអត្ថន័យជាមួយសង្គមស៊ីវិល។<br>មាត្រា២២នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយបានកំណត់អំពីដែនកំណត់របស់រដ្ឋាភិបាលដែលមានកំណត់យ៉ាងច្បាស់នៅក្នុងឃ្លា "គ្មានការរិតត្បិតអាចធ្វើបានចំពោះការអនុវត្តសិទ្ធិនេះ (សេរីភាពនៃការបង្កើតសមាគម) ឡើយ ក្រៅពីមានការចែងនៅក្នុងច្បាប់ និងមានភាពចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យដើម្បីផលប្រយោជន៍សន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈឬសីលធម៌ ឬការការពារសិទ្ធិសេរីភាពអ្នកដទៃ"។ ការទទួលស្គាល់សិទ្ធិបង្កើតសមាគម ដូចសិទ្ធិមួយ "ដែលត្រូវតែគោរពចាំបាច់ វាលែងតែកម្រិតសិទ្ធិនេះមានកំណត់នៅក្នុងច្បាប់….. សារៈសំខាន់បំផុតនៃសេរីភាពសមាគមនៅក្នុងសមត្ថភាពនៃសិទ្ធិទាំងនោះជាកម្មសិទ្ធិរបស់បុគ្គលគ្រប់រូបដើម្បីសម្រេចថាតើធ្វើវាយ៉ាងដូចម្តេច ភាពចាំបាច់នេះគឺការកំណត់នូវជំហ៊ាននៃវិធានដ៏តិចតួច និងពិនិត្យលមលើយ៉ាងកៀកកិតក្នុងគោលបំណងជ្រៀតជ្រែកជាមួយនឹងការជ្រើសរើសដែលសមាគម និងសមាជិករបស់ពួកគេធ្វើការរៀបចំការងារផ្ទាល់របស់ពួកគេ[8]។<br><br>**មាត្រា ២៥៖ ការធ្វើសវនកម្មសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល**<br>**ចំណោទ**<br>តើរដ្ឋាភិបាលអាចធ្វើសវនកម្មសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែរឬទេ?<br>**ការវិភាគ**<br>សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលគ្មានកាតព្វកិច្ចហិរញ្ញវត្ថុចំពោះរដ្ឋាភិបាលទេ បើគេមិនបានទទួលជំនួយពីរដ្ឋាភិបាលទេ។ រដ្ឋាភិបាលអាចធ្វើសវនកម្មហិរញ្ញវត្ថុ តែក្នុងករណីណាដែលមានការសង្ស័យរឿងព្រហ្មទណ្ឌ ហើយអាចធ្វើបានក្នុងក្របខណ្ឌនៃការស៊ើបអង្កេតផ្នែកតុលាការ។ | |
| ១៩ | ២៩ | **មាត្រា ២៩៖ ការរំលាយដោយតុលាការនិង ការបញ្ចប់ដោយអនុស្សារណៈមុនចប់រយៈពេលនៃអនុស្សារណៈ** | |

[8] Public Interest Law Initiative, *Enabling Civil Society: Practical Aspects of Freedom of Association,* (Butapest 2003), p.42. Recommendation CM/Rec (2007)14 of the Committee of Ministers of the Council of Europe states, in section VII (#70) that “No external intervention in the running of NGOs should take place unless a serious breach of the legal requirement applicable to NGOs has been established or it reasonably believed to be imminent.”

| | | | |
|---|---|---|---|
| | | មាត្រា ២៩ កំណត់អំពីប្រភពនៃធនធាន និងទ្រព្យសម្បត្តិ នៃសមាគម និងអង្គការក្នុងស្រុកនៅក្នុងហានិភ័យនៃការរិបអូស ការរំលាយសមាគម ឬអង្គការក្នុងស្រុក ឬការលុបចោលអាចធ្វើការតវ៉ាទៅតុលាការដែលត្រូវធ្វើនៅគ្រប់តំណាក់កាលនៃសេចក្តីសម្រេចរបស់តុលាការដែលទាក់ទងនឹងការចាត់ចែងទ្រព្យសម្បត្តិ និងធនធាន។ នេះជាហានិភ័យមួយលើសកម្មភាពទ្រព្យសម្បត្តិផងដែរដែលរារាំងលើការតវ៉ាចំពោះសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ។ | |
| ២០ | ៣០ | **មាត្រា ៣០៖ ការដាក់ទណ្ឌកម្មចំពោះការធ្វើសកម្មភាពដែលធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ សុវត្ថិភាពសាធារណៈ។ល។**<br>មាត្រា ៣០ បានកំណត់អំពី អង្គការក្នុងស្រុកអាចនឹងត្រូវបានលុបចេញពីបញ្ជីក្នុងករណីដែលគេរកឃើញថា អង្គភាពនេះមិនអព្យាក្រិត្យ ព្រមទាំងអង្គការនេះមិនបានដាក់របាយការណ៍ដែលជាកាតព្វកិច្ចនោះ។ មាត្រា ៣០ក៏បានកំណត់នៅអំណាចឆន្ទានុសិទ្ធិដ៏ធំធេង និងប្រើពាក្យមិនច្បាស់លាស់ដែលផ្តល់អំណាចឲ្យក្រសួងមានសិទ្ធិលុបអង្គការ ឬសមាគមក្នុងស្រុកបាន ដោយយកលេស សកម្មភាព ឬកម្មវត្ថុនៃអង្គភាពនោះធ្វើឲ្យប៉ះពាល់ដល់សន្តិភាព ស្ថេរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិ ឯកភាពជាតិ ទំនៀមទំលាប់ និងប្រពៃណីរបស់សង្គមកម្ពុជា។ រដ្ឋាភិបាលក៏អាចព្យួ ឬលុបសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកផងដែរចំពោះអង្គភាពដែលរំលោភបំពានលើលក្ខខន្តិកៈរបស់ខ្លួន។ | |
| | | **មាត្រា ៣១៖**<br>មាត្រា ៣១ គួរកែប្រែឡើងវិញដើម្បីធានាថា យោងលើការជម្រះបញ្ជី ទ្រព្យសម្បត្តិទាំងឡាយត្រូវបានផ្ទេរទៅឲ្យអង្គការដែលមានគោលបំណងដូចឬប្រហែលនឹងអង្គភាពរបស់ខ្លួន។ ដូច្នេះមាត្រា ៣១ គួរប្តូរទៅជា "ដោយផ្អែកលើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលត្រូវបានរំលាយដោយសេចក្តីសម្រេចរបស់តុលាការ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីដោយសេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ ការជម្រះបញ្ជីលើកាតព្វកិច្ច និងការចាត់ចែងចំពោះទ្រព្យដែលនៅសល់អាចផ្ទេរទៅសមាគម ឬអង្គការមិនមែនក្នុងស្រុកដែលមានគោលបំណង ឬទិសដៅស្រដៀងគ្នា។<br>**មាត្រា ៣២៖ ការដាក់ទណ្ឌកម្មចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលមិនបានចុះឈ្មោះ** | |

| | | | |
|---|---|---|---|
| | | **ចំណោទ**<br>តើច្បាប់ទទួលស្គាល់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានទម្រង់ក្រៅផ្លូវការដែរឬទេ?<br>**ការវិភាគ**<br>មាត្រា ៣២ ចែងថា ក្រសួងមហាផ្ទៃត្រូវចាត់ការបញ្ឈប់សកម្មភាពរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ដែលមិនបានចុះបញ្ជី។ បើសិនជាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលទាំងនោះបន្តសកម្មភាពទៀត គេត្រូវពិន័យជាប្រាក់ ពី ៥ ទៅ ១០ លានរៀល (១,២៥០ ដល់ ២,៥០០ ដុល្លា) ហើយអាចរងការចោទប្រកាន់តាមផ្លូវព្រហ្មទណ្ឌទៀតផង។ ទណ្ឌកម្មទាំងនេះក៏អនុវត្តចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលណាដែលបន្តសកម្មភាពបន្ទាប់ពីត្រូវបានបញ្ជាឲ្យផ្អាក ឬ លុបចេញពីបញ្ជី។<br>មាត្រានេះ នឹងមានផលប៉ះពាល់ដល់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលមានទម្រង់ក្រៅផ្លូវការ ដែលច្បាប់នេះមិនទទួលស្គាល់អត្ថិភាពរបស់គេ។<br>សំរាប់ការវិភាគបន្ថែម សូមមើលក្នុងការវិភាគ នៅក្នុងមាត្រា ៨ ខាងលើ។ | |
| ២១ | ៣៣ | **មាត្រា ៣៣៖ ទណ្ឌកម្មចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលមិនបានដាក់របាយការណ៍ស្តីពីពត៌មាន គណនី និងការប្តូរអាសយដ្ឋាន តំណាង ការមិនប្រកាន់ជំហរអព្យាក្រិត្យភាព និង ការដាក់របាយការណ៍សកម្មភាពនិងហិរញ្ញវត្ថុប្រចាំឆ្នាំ**<br>មាត្រា ៣៣ គួរតែប្រែចំពោះទណ្ឌកម្មសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស ដោយសេចក្តីជូនដំណឹងពី ក្រសួងចំនួន៣០ថ្ងៃក្នុងការចង្អុលបង្ហាញថាអំពីការបញ្ចប់អនុស្សារណៈ។ មូលដ្ឋាននៃការបញ្ចប់អនុស្សារណៈរួមមានការបន្តមិនព្រមផ្ញើររបាយការណ៍ហិរញ្ញិកដូចមានកំណត់នៅក្នុងមាត្រា ១៧ និងមាត្រា២៥ និងភាពមិនអាព្យាក្រិត្យដែលមាននៅក្នុងលក្ខខណ្ឌនៃមាត្រា ២៤។<br>ចំណុចដែលសំខាន់នោះគឺ សេចក្តីព្រាងច្បាប់នេះខ្វះនូវប្រព័ន្ធការពារដ៏សំខាន់មួយ (*ឧទាហរណ៍ កម្មវត្ថុស្តង់ដារសម្រាប់ការពិនិត្យ និងការបដិសេធលើការចុះបញ្ជី ការពន្យល់ជាលាយលក្ខណ៍លើករណីបដិសេធមិនចុះបញ្ជី និងសិទ្ធិតវ៉ាទៅតុលាការមានសមត្ថកិច្ច និងឯករាជ្យ*) សម្រាប់ការចុះបញ្ជីអង្គការមិនមែនរដ្ឋាភិបាលបរទេស។ ព្រមជាមួយគ្នានោះដែរ ដំណើរការនៃការចុះបញ្ជីដែលមានពហុតំណាក់កាលសម្រាប់អង្គការបទេសអាចជាហេតុធ្វើឲ្យមានការយឺតយ៉ាវ និងជាកម្មវត្ថុនៃការសម្រេចដោយឆន្ទៈផ្ទាល់ខ្លួន ការ | |

| | | | |
|---|---|---|---|
| | | សម្រេចតាមចិត្ត និងការសម្រេចដោយធ្វើតាមនយោបាយ។ បន្ថែមចំណុចនេះសូមអានការវិភាគលើ មាត្រា ១០ មាត្រា ២៤ និងមាត្រា ២៥។ | |
| ២២ | ៣៤ | **មាត្រា ៣៤៖ វិធានការលើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសដែលមិនបានចុះបញ្ជី**<br>មាត្រា ៣៤ បានបញ្ជាក់ជាថ្មីម្តងទៀតថា អាជ្ញាធរពាក់ព័ន្ធត្រូវចាត់វិធានការចំពោះសមាគម ឬ អង្គការបរទេសដែលធ្វើការដោយមិនបានចុះបញ្ជី ឬបន្តធ្វើសកម្មភាពក្រោយពេលអស់សុពលភាពនៃអនុស្សារណៈ។ បុគ្គលិកបរទេសដែលបន្តធ្វើការ ឲ្យអង្គការ ឬសមាគមបទេសដែលមិនបានចុះបញ្ជីអាចត្រូវបណ្តេញចេញ និង ឬកម្មវត្ថុឲ្យមានទណ្ឌកម្មផ្នែកព្រហ្មទណ្ឌទៀតផង។<br>មាត្រានេះធ្វើឲ្យមានហានីភ័យដល់បុគ្គលិកអង្គការបរទេសដែលធ្វើការលើវិស័យស៊ើបអង្កេត ដោយដាក់ពួកគេនៅកន្លែងមួយដែលរងការគម្រាមកំហែងនៃការបណ្តេញចេញយ៉ាងទាន់ហន់ ប្រសិនបើអង្គការនោះត្រូវបានគេលុបឈ្មោះចេញភ្លាមៗ។ | |
| ២៣ | ៣៥ | **មាត្រា ៣៥៖ ការបញ្ចប់អនុស្សារណៈជាមួយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេស**<br>មាត្រា ៣៥ ផ្តល់អំណាចដល់ក្រសួងការបរទេសបញ្ចប់អនុស្សារណៈ "ក្នុងពេលដែលសមាគម ឬ អង្គការបរទេសធ្វើសកម្មភាពដែលធ្វើឲ្យប៉ះពាល់ដល់សន្តិភាព ស្ថេរភាព និងបណ្តាប់ធ្នាប់សាធារណៈ ឬធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិ ឯកភាពជាតិ វប្បធម៌ និងទំនៀមទំលាប់សង្គមកម្ពុជា"។ មូលដ្ឋាននៃការបញ្ចប់សុពលភាពអនុស្សារណៈនេះមានភាពមិនច្បាស់លាស់ ហើយអាចជាកម្មវត្ថុនៃការបកស្រាយតាមទំនើងចិត្ត។ តើត្រូវបកស្រាយយ៉ាងណាចំពោះពាក្យ "ឯកភាពជាតិ វប្បធម៌ ទំនៀមទំលាប់ និងប្រពៃណីសង្គមកម្ពុជា?" តើវានឹងមានការកម្រិតនូវស្តង់ដាមិនច្បាស់លាស់ដល់អង្គការបរទេសដែលធ្វើការតស៊ូមតិលើបរិស្ថាន សិទ្ធិមនុស្ស ឬការការពារការឃ្លាំមើល? ស្តង់ដារដែលអាចអនុវត្តដើម្បីលុបចោលអង្គការក្នុងស្រុកអាចអនុវត្តលើ "អាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធគួរតែបង្ហាញផ្លូវ ដោយស្តង់ដារជាក់លាក់ និងរិតត្បិតចំពោះការសម្រេចតាមទំនើងចិត្ត"[9]។ បន្ថែមពីលើនេះទៀត គ្មានលក្ខខណ្ឌសម្រាប់អាជ្ញាធររដ្ឋាភិបាល | |

[9] ICNL and the World Movement for Democracy Secretariat at the National Endowment for Democracy, *Defending Civil Society: Report of the World Movement for Democracy* (2008), p.31; *see also,* Report submitted by the UN Special Representative of the Secretary-General on human rights defenders, Hina Jilani, in accordance with General Assembly resolution 58/178, p.23 ("Actions by the Government against NGOs must be appropriate and subject to appeal and judicial review. Administrative irregularities…should never be considered as sufficient grounds for closing down an organization.")

| | | | |
|---|---|---|---|
| | | ដើម្បីផ្តល់នូវសេចក្តីជូនដំណឹង ឬផ្តល់ឱកាសដើម្បីធ្វើការកែតម្រូវបញ្ហាមុនពេលព្យួរ ឬបញ្ចប់អនុស្សារណៈ និងគ្មាននិយាយអំពីសិទ្ធិតវ៉ាបន្ទាប់ពីព្យួរ ឬបញ្ចប់សុពលភាពអនុស្សារណៈឡើយ។ ព្រមជាមួយនឹងដំណើរការនៃការលុបចោលសុពលភាពអនុស្សារណៈគឺបើកដៃឲ្យរដ្ឋាភិបាលក្នុងធ្វើសេចក្តីសម្រេចចិត្តតាមទំនើងចិត្ត។<br>ប្រតិបត្តិការនិងឋានៈគតិយុត្តរបស់សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបរទេសត្រូវបានកំណត់ដោយសិទ្ធិនិងករណីយកិច្ចដែលចែងនៅក្នុងអនុស្សារណៈ។ ការបញ្ចប់ត្រូវផ្អែកលើ ខ និង លក្ខខណ្ឌ ដែលព្រមព្រៀងគ្នាទៅវិញទៅមករវាងរដ្ឋាភិបាល និងសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលទាំងនោះ។<br>សកម្មភាព និងឋានៈផ្លូវច្បាប់នៃសមាគម ឬអង្គការបរទេសត្រូវបានកំណត់ដោយសិទ្ធិ និងកាតព្វកិច្ចកិច្ចសន្យាដែលមានចែងនៅក្នុងអនុស្សារណៈយោគយល់គ្នា។ ការបញ្ចប់សុពលភាពគួរផ្អែកលើខ្លឹមសារ និងលក្ខខណ្ឌនៃព្រមព្រៀងគ្នារវាង រដ្ឋាភិបាល និងសមាគម ឬអង្គការបរទេសទាំងនោះ។ | |
| ២៤ | ៣៦ | **មាត្រា ៣៦៖ បទល្មើសដែលប្រព្រឹត្តដោយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល**<br>មាត្រា ៣៦ បានចែងអំពីភាពមិនចាំបាច់នៃសារៈសំខាន់ចំពោះទណ្ឌកម្មព្រហ្មទណ្ឌដល់សមាគម ឬអង្គការក្នុងស្រុកដែលធ្វើសកម្មភាពដែលធ្វើឲ្យប៉ះពាល់ដល់សន្តិភាព ការលាងលុយ ហិរញ្ញប្បទានភេរវកម្ម ឬបទល្មើសភេរវកម្ម។ | |
| ២៥ | ៣៧ | **មាត្រា ៣៧៖ ឋានៈគតិយុត្តនៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបច្ចុប្បន្នត្រូវបានទទួលស្គាល់ដោយមិន បាច់ចុះបញ្ជី**<br>**ចំណោទ**<br>តើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលបច្ចុប្បន្នដែលមិនបានតំកល់ឯកសារចុះបញ្ជីជាមួយក្រសួងមហាផ្ទៃត្រូវបានទទួលស្គាល់ថាបានចុះបញ្ជីដែរឬទេ?<br>**ការវិភាគ** | សេចក្តីព្រាងច្បាប់ត្រូវដាក់បញ្ចូលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលបានតំកល់ឯកសារ ឬការយល់ព្រមជាមួយស្ថាប័នរដ្ឋាភិបាលដទៃទៀតដើម្បីឲ្យគេអាចបន្តអត្ថិភាពជានីតិបុគ្គលដោយមិនបាច់ចុះបញ្ជីសាជាថ្មី។ ចំពោះសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលណាដែលមិនបានទាក់ទងជាមួយក្រសួង |

| | | | |
|---|---|---|---|
| | | ការជាក់ស្តែង មានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលខ្លះបានតំកល់ឯកសាររបស់គេជាមួយក្រសួងមហាផ្ទៃ ហើយមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាលខ្លះទៀតទទួលបានលិខិតអនុញ្ញាតដោយទីស្តីការគណៈរដ្ឋមន្ត្រី ឲ្យធ្វើសកម្មភាពជាសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល។<br>សេចក្តីព្រាងច្បាប់នេះ បញ្ជាក់តែពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលបានតំកល់ឯកសារជាមួយក្រសួងមហាផ្ទៃប៉ុណ្ណោះ។ បើច្បាប់នេះអនុវត្តដូចអក្សរសរសេរនៅក្នុងច្បាប់នេះ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាលដែលទទួលបានការអនុញ្ញាតពីទីស្តីការគណៈរដ្ឋមន្ត្រី នឹងត្រូវចុះបញ្ជីសាជាថ្មីជាមួយក្រសួងមហាផ្ទៃ។ | មហាផ្ទៃពីមុនមកទេ ត្រូវដាក់លិខិតយល់ព្រមរបស់គេ ដើម្បីជាឯកកសាររបស់ក្រសួងមហាផ្ទៃ។ |
| ២៦ | ៣៩ | **មាត្រា៣៩៖ សេចក្តីព្រាងច្បាប់នេះនិរាករណ៍ច្បាប់ដទៃទៀតដែលជំទាស់ជាមួយខ្លួន**<br>**ចំណោទ**<br>តើសេចក្តីព្រាងច្បាប់នេះមានអំណាចនិរាករណ៍ច្បាប់ដទៃទៀតដែរឬទេ?<br>**ការវិភាគ**<br>មាត្រានេះចែងថា បទបញ្ញត្តិដទៃទៀតដែលផ្ទុយនឹងច្បាប់នេះត្រូវចាត់ទុកជានិរាករណ៍។ នេះជាការនិរាករណ៍ដោយមិនបាច់រើសមុខនូវច្បាប់ដទៃទៀត ដែលរួមមានរដ្ឋធម្មនុញ្ញ ក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌ កតិកាសញ្ញាអន្តរជាតិនានា។ល។<br>ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាលនេះ នឹងធ្វើឲ្យមាត្រា ៣៥, ៤១, ៤២, និង ១២៨ នៃរដ្ឋធម្មនុញ្ញ មាត្រា ១៩ និង ២២ នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ មាត្រា ៥៥, ៥៦, នៃក្រមព្រហ្មទណ្ឌ មាត្រា ៤៦ និង ៦៩ នៃក្រមរដ្ឋប្បវេណី លែងមានប្រសិទ្ធភាព ឬមិនអាចអនុវត្តបាន។ | មាត្រា ៣៩ នៃសេចក្តីព្រាងច្បាប់នេះ រំលោភលើរដ្ឋធម្មនុញ្ញ និង ធ្វើឲ្យខូចខាតដល់សន្តិសុខគតិយុត្តនៃច្បាប់ដទៃទៀត។ |